វិញ» តើការសង្កេតនេះមានសេចក្ដីពិតឬទេ? ។ ៤) ការមកសិក្សានៅសាលារៀនមានវត្ថុបំណងធំប៉ុន្មានយ៉ាង?

---

# ត្រូវរក្សាសាមគ្គីធម៌រវាងអ្នកក្រ

(បទព្រហ្មគីតិ)

អ្នកមានរក្សាខ្សត់ ដូចសំពត់ព័ទ្ធពីក្រៅ
អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនូវសំប៉ាន ។
អ្នកខ្ពស់រក្សាទាប ដោយសភាពធម៌បូរាណ
អ្នកផ្អែករក្សាឃ្លាន នាអ្នករងរក្សាធ្ងារ ។
រក្សាទៅមករឹង ឥតកំដឹងអស់អម្ពាល
បំណាចចិរកាន់កាល ដូចរបងបាចបន្ទា ។
កុំផ្អែកពេកតែឯង មិនគិតក្រែងអស់គ្នីគ្នា
គេឃ្លានៗផ្ទៃផ្សា ឲ្យស៊ីក៏បានផ្អែកផង ។
កុំមានចិត្តលលើ ពឹងក្រពើឲ្យចម្លង
កុំកាច់ទសរបង រាំងចំណារឯគាគ្នា ។

មានទូកហើយមានថ្នោល មានបង្គោលមានយុថ្កា

ទាំងពួរទាំងច្រវ៉ា គ្រឿងចាប់ដោយនូវគ្រប់ ។

ប្រយ័ត្នក្រែងមានខ្យល់ បក់បោកដល់ទឹងទល់ទប់

ប្រយ័ត្នប្រយោជន៍គ្រប់ ទើបហៅជាតិជាកំណើត ។

ច្បាប់ពាក្យចាស់

---

## ក) ពន្យល់ពាក្យនិងសំនួនវោហារ

១) អ្នកមានគ្រាខ្សត់ ។ ២) អ្នកប្រាជ្ញគ្រាខ្លៅ ។ ៣) អ្នកខ្ពស់គ្រាទាប ។ ៤) អ្នកឆ្អែតគ្រាឃ្លាន ។ ៥) នាអ្នករឹងគ្រាធ្លារ ។ ៦) ឥតកំដឹងអស់អម្បាល ។ ៧) កុំមានចិត្តលលើ ពឹងក្រពើឲ្យចម្លង ។ ៨) កុំកាប់ឫសរបងរាំងចំណារឯអាត្មា ។ ៩) គ្រឿង ។ ១០) ទើបហៅជាតិជាកំណើត ។

## ខ) សំនួរ

១) ហេតុដូចម្ដេច បានជាអ្នកនិពន្ធ ទុកអ្នកខ្សត់ដូចជាសំពត់? ទុកអ្នកខ្លៅដូចសំប៉ាន?

២) បើគ្មានថ្នោល - បង្គោល - ត្បូរ - យុថ្កា - ប្រវាំទីងក្រដីង តើទូកទីងគាចប្រព្រឹត្តទៅបានឬទេ? ៣) សម្ភារៈទាំងនេះ បើដោយអត្ថបដិរូបគួរទុកជាអ្វី?

## គ) អត្ថរសទូទៅ

អ្នកនិពន្ធដែលតែងអត្ថបទនេះ មានគោលបំណងនឹងឲ្យគតិដល់យើងដូចម្ដេច?

## ឃ) និពន្ធសេចក្ដី

ចូរអត្ថាធិប្បាយនូវសុភាសិត «អ្នកខ្លួសក្រោមទាប ដោយសភាពធម៌បុរាណ អ្នកផ្ដេតក្រោយឃ្លាន នាអ្នកនៅក្រោមគ្នារ» ដោយយកឧទាហរណ៍មកជាគ្រឿងតាង ។

---

## គុណគ្រូ

(បទកាកគតិ)

| | | |
|---|---|---|
| គ្រូបាធ្យាយ | ប្រដូចនូវម្ដាយ | ខំពុកឯងហោង |
| ហ្វឹកហ្វឺនប្រដៅ | មិនឲ្យមានគ្គង | តាមដោយគន្លង |

ព្រេងព្រទ្ធបូរាណ ។

នរអ្នកណា ទឹងស្វែងប្រាជ្ញា ជារស្មីប្រាណា
ឲ្យគិតផញ្ចឹង រំពឹងវែងបាន កុំធ្វើបំពាន
ប្រទូស្តវិនស្នង ។

នាបីហៅគ្រូ ដូចអ្នកនាំផ្លូវ ដើរដោយគន្លង
ទោះទឹងឆ្ពោះទៅ ស្រុកតូចធំផង សឹងដូចបំណង
នៃចិត្តចិន្តា ។

រីទឹងបេះឯង ដូចអ្នកវង្វេង កណ្ដាលអធ្វា
ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា បរចេញយាត្រា
ឥតអ្នកដឹកដៃ ។

សូម្បីរកផ្លូវ ពុំដែលនឹងត្រូវ សឹងពានឯព្រៃ
ហេតុដ្បិតបេះឯង ឥតអ្នកដឹកដៃ ចិត្តនោះសង្ស័យ
ដូចដល់ពុំដល់ ។

នេះដូចអ្នកផង ពុំដោយគន្លង នៃលោកណាយល់
សឹងធ្វើមោហោ ទោសោកំហល់ ពុំអាចទប់ទល់
នាធ្ងន់នាស្រាល ។ ច្បាប់ក្រម

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) តាមដោយគន្ធន៍ ព្រេងព្រឹទ្ធបុរាណ ។ ២) នរអ្នកណា ។ ៣) ដារស្មើប្រាណ ។ ៤) រំពឹងលែងបាន ។ ៥) ប្រទូស្តរឹងស្អួង ។ ៦) នាបី (នាបីហៅគ្រូ) ។ ៧) នៃចិត្តចិន្តា ។ ៨) អង្វា ។ ៩) ដូចដល់ពុំដល់ ។ ១០) នៃលោកណាយល់ ។ ១១) ពុំអាចទប់ទល់ នាធ្ងន់នាស្រាល ។

## ខ) សំនួរ

១) អ្នកនិពន្ធប្រដូចគ្រូទៅនឹងមាតាបិតា ដោយប្រការម្តេច ? –
២) ហេតុអ្វីបានជាអ្នកនិពន្ធប្រដៅថា កុំឲ្យប្រទូស្តតបទៅនឹងគ្រូឯង? –
៣) ដូចម្តេចបានជាអ្នកនិពន្ធទុកគ្រូជាអ្នកនាំផ្លូវ? ៤) ដោយប្រការយ៉ាងណា ក៏អ្នកនិពន្ធទុកអ្នករៀនឥតគ្រូ ដូចជាមនុស្សខ្វាក់? ៥) ក្នុងលោកយើង តើមានបុគ្គលណាម្នាក់ ដែលចេះដឹងដ៏ពិតប្រាកដ ដោយឥតពឹងគ្រូ?

## គ) អត្ថរសទូទៅ

អ្នកនិពន្ធដែលសាងអត្ថបទនេះមក មានគោលបំណងចង់ឲ្យសិស្សទាំងឡាយយល់ច្បាស់ ដោយប្រាសចាកការកាន់ច្រឡំ ថាគ្រូជាបុគ្គលដូចម្តេចក្នុងលោក។

# ច្បាប់ទូន្មាននារី

(ពាក្យ ៨)

កំពុងពេញពាលរូបតរុណរាគ្យ　　បំរើនសក្តិកមលក្ខណ៍ជាស្ត្រី
គួរប្រព្រឹត្តតាមយ៉ាងព្រហ្មចារី　　រក្សាកាយកុំបីឲ្យហ្មងសៅ ។
សេចក្តីជួគួរជំរុះពីរូបចេញ　　សេចក្តីល្អគួរបំពេញឲ្យមាននៅ
តាំងចរិតប្រព្រឹត្តឲ្យត្រឹមត្រូវ　　នឹងតវង្សពង្សផៅជាមង្គល ។
ស្ត្រីណាកើតក្នុងព្រះវង្សខ្ពស់　　បំរុងយសថ្កមកាយ ហ្វាយយកផល
គោងសួនចិត្តកុំបើកទៅតាមកល　　ទើបមិនពាល់ពាក្យតិះអ្នកដទៃ ។
ខ្លួនតរុណពេញជំទង់វង្សនារី　　ដូចមណីសូរ្យកាន្តមានដម្លៃ
មែនបើបែកប្រែកប្រេះកាលណានៃ　　ក៏ថយថ្លៃចុះថោករកលក់ក្រ ។
ឯគួរចាប់កុំទៅប្រឹងឲ្យខ្ពស់ប្រាណ　　មើលសន្តានតាមសណ្តាប់បែបអ្នកល្អ
នឹងស្លៀកពាក់សំពត់អាវពណ៌ខ្ចៅស　　តែងកាយក៏មើលកាយឲ្យម៉ត់ហ្មង ។
ការតែងគួរសុភាពរៀបគាប់គល　　នរណាយល់ចង់សរសើរថាខ្លួនល្អ
បេះតែងប្រាណត្រូវប្រមាណមិនមានផ្គង　　ចុះទំនងមយូរមេសមសណ្ឋាន ។
មែនរូបល្អសសមឧត្តមសក្តិ　　តែមិនបេះទុកដាក់ឲ្យសមប្រាណ
គង់មិនស្អះកាយស្ទើតឆើតទៅបាន　　ខុសសណ្ឋានឥន្ទ្រីយ៍ធរីវណ្ណ ។

ប្រការមួយទោះដើរដំណើរនាង សន្សឹមយាសយាងបាទបរដោយដាន់
កំបង់ពោយផ្ការហត្ថក្រពាត់ពន្ធ កុំបើកឋនបន្ទយថ្នក់ក្រោមផ្ចិត ៗ
កុំដើរក្រាយកាយយោកឆោកខ្ញឹកខ្ញក់ កុំសិតសក់កណ្ដាលផ្លាមិនស្និទ្ធ
ឃើញកៀនមក៍កុំលលេងតាមចិត្ត មកសាន្តស្និតស៊ីមគិតប្រឹក្សាគ្នា ៗ
ឲ្យកំណាត់កត់ចាំពាក្យណាគាប់ កុំបីគ្រាប់ពាក្យពុតពោរពាលា
កុំនិយាយឡោះឡេះកេះកៀវគ្នា កុំនាំពារក្រៅក្នុងចេញចូលស្ថាន ៗ
ទីកូមិណាស្រីជួមិនគួរបរ ទៅអបអរពេបរកើជាសន្តាន
ទីកូមិណាប្រុសដុំកុំលលាន ធុះមានរកចាស់គេជូនទៅ ៗ
ចូររាំងការកេតិ៍កុំបេះបរ តាមផ្ទះពួកនិករសាប់ញាតិផៅ
កុំឡើងផ្ទះញាតិមិត្រឥតគេហៅ តែគ្រាប់ទៅញយ ៗ គន់ថយសក្តិ ៗ
នឹងអគ្គុយឲ្យស្រគត់ស្រគំកាយ កាលនិយាយកុំលាយសើចលោក
កើតជាស្រីក្ដីខ្វាសមានច្រើនថ្នាក់ ចូរស្ងួនសក្ដិរក្សាការក្ដីហ្វង ៗ
នយ:នេត្រកុំសង្កេតឲ្យគឹនណាស់ មើលតែបព្រាស់យល់ដាក់ដាក់វិញហោង
បើផ្ទុកទៅយល់អស់កំឡោះផង កុំមៀងហ្វងផ្អងផ្អៀងសំឡឹងគន់ ៗ
ឯនេត្រានាំអាត្មាឲ្យមួហ្វង ដូចទំនងនេះនាំឲ្យសម្ព័ន្ធ
ពិតមិនពិតគេក៏ជិតចិត្តចៅលន់ ពាលៈជនប្រមាថមារយាទបាន ៗ

ឧកញ៉ាសុត្តន្តប្រីជាឥន្ទ

(សុភាសិតច្បាប់ស្រី)

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) រូបគរុណាគេ្យ ។ ២) ព្រហ្មចារី ។ ៣) ចរិត ។ ៤) ហ្មាយយកផល ។ ៥) គោធស្ងួនចិត្ត ។ ៦) មណីសូវ្យកាន្ត ។ ៧) មយូរមេសមសណ្ឋាន ។ ៨) ឥន្ទ្រីយ៍ធរីវណ្ណ ។ ៩) កុំបើកថន ។ ១០) ស្រីដួ ។ ១១) នយនេត្រ ។ ១២) នាំឲ្យសម្ពន្ធ ។

## ខ) សំនួរ

១) យ៉ាងដូចម្ដេច ហៅថា: «កុំបើកទៅតាមកល»? ២) អ្នកនិពន្ធប្រៀបនារីទៅនឹង «មណីសូវ្យកាន្តមានតម្លៃ» តើការប្រៀបធៀបនេះមានសភាពសមរម្យឬទេ? ៣) «ឯគួរខាបកុំទៅប្រើឲ្យខ្ពស់ប្រាណ» តើអ្នកនិពន្ធមានគោលបំណងយ៉ាងណា? ៤) យ៉ាងដូចម្ដេច ហៅថា «បង់ចោយផ្កាហេតុក្រពាត់ពន្ធ»? ៥) សំដីដូចម្ដេចខ្វះ ជាសំដី «ពុតពោរពាលា»? ៦) ពាក្យថា: « តែគ្រាប់ទៅញយៗ គង់ថយសក្តិ » តើព្រោះហេតុអ្វី? ៧) ពាក្យកាព្យចុងក្រោយបង្អស់: «ពាលៈជនប្រមាថមារយាទបាន» តើប្រមាថគង់នយដូចម្ដេច?

## គ) ផែនការ

ចូរសង្កេតពិនិត្យមើល តើអត្ថបទនេះ នឹងអាចចែកបានជាប៉ុន្មានសង្កាត់? តើសង្កាត់នីមួយ ៗ ពោលអំពីអ្វី?

## ឃ) វេយ្យាករណ៍

១) ចូរពិនិត្យពាក្យ «សត្រី» (ចំរើនសក្តិគបលក្ខណ៍ជាសត្រី) បើតាមច្បាប់អក្ខរាវិរុទ្ធ តើត្រឹមត្រូវឬទេ? គង់ទីនេះអ្នកនិពន្ធសរសេរដូច្នេះ ព្រោះហេតុអ្វី? ២) ចូររកពាក្យជាវេវចនៈ នឹង «តរុណា» នឹង «ប្រមាថ» ៣) ចូររកពាក្យជាសទិសសព្ទនឹងពាក្យ «ពុត» (ពុតពោរពណា) ។

---

# ក្បាច់ចម្លាក់នគរវត្ត

(ពាក្យ ៨)

មើលមណ្ឌលពេញទងទំនងស៊ុម  ជញ្ជាំងជុំសឹងជិតជាចម្លាក់
ជារូបរឿងរាមកេរ្តិ៍គឺរាមលក្ស្មណ៍  ច្បាំងនឹងយក្សក្រុងរាពណាសូរ ។
ស្វាប្រតាក់យក្សប្រតាប់ពប់រង្គា  ស្វាក្រទីយក្សក្រពាកាប់ផ្គាស់ប្តូរ
យក្សប្រជិតស្វាប្រជាប់ចាប់កំពូល  ស្វាប្រជាល់យក្សដួលដេកក្សិណក្ស័យ ។

គន់គំនូររឿងរាមសង្គ្រាមយក្ខ　　ជាអនគ្ឃមើលអនេកអនន្តក្រៃ

ជ្រុងទក្សិណគូរកាលសហស្សន័យន៍　　គង់នៅឰកៃលាសវិមានច័ន្ទ ៗ

កៃលាសផ្អៀងផៀងធ្លាក់ព្រះសូលី　　ប្រើក្រុងរាពណ៍អសុរីពជកម្ពុជ

ដៃម្ភៃមុខដប់រូបសកន្ធ　　ឲ្យតម្រង់ប្រាង្គណ៍ច័ន្ទកៃលាសហ៊ាន ៗ

រាពណានេរមិតរិទ្ធិសាហ័ស　　តម្រង់ភ្នំកៃលាសឡើងត្រង់បាន

ព្រះឥស្សូរក៏ទ្រង់ព្រះរាជទាន　　នាងមណ្ឌោគល្យាណជាភរិយា ៗ

ផ្ដែរខាងបូព៌ាគូរកាលសុគ្រីពយំ　　អង្វរអង្គព្រះបរមរាមា

ឲ្យជួយផ្ចាញជីវិតនៃស្ដេចស្វា　　ក្រុងពាលីជេដ្ឋាបច្ចាមិត្រ ៗ

ព្រះរាមក៏បចាប់ធ្នូរវៃថ្ងងសរ　　បាញ់ពានរពាលីសូន្យជីវិត

គួរទាំងពួកនារីស្រីស្នំស្និទ្ធ　　សោកអាណិតសែនអាណោចរខ្លោចពាលី ៗ

ឯសុគ្រីពរិទ្ធិរុទ្ធបុត្រសុរិយា　　ក៏សោកានៅទៀបព្រះខែនទី

អញ្ជើញអង្គរាមាចូលធានី　　តាំងពិធីលើកសពពានរ ៗ

ឧកញ៉ាសុត្តន្តប្រីជាឥន្ទ
(និរាសនគរវត្ត)

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ពេងទង ។ ២) ពពណាសូរ ។ ៣) ជាអនគ្ឃ ។ ៤) សហស្សន័យន៍ ។ ៥) កៃលាស ។ ៦) ព្រះសូលី ។ ៧) រូបសគន្ធ ។ ៨) រិទ្ធិសាហ័ស ។ ៩) ផ្គរ ។ ១០) សុគ្រីព ។ ១១) ក្រុងពាលី ។

## ខ) សំនួរ

១) តាមធម្មតា សហស្សន័យន៍ គឺជានរណា។ ហើយក្នុងទីនេះ គឺជានរណា។ ២) សុគ្រីពបានជាយំ ព្រោះហេតុអ្វី។ ៣) ដែលព្រះរាមទៅស្ដាប់សេចក្ដីអង្វរសុគ្រីព ហើយទៅបាញ់សម្លាប់ក្រុងពាលី ជាអ្នកឥតសត្រូវនឹងព្រះអង្គ តើសមរម្យតាមច្បាប់មនុស្សធម៌ឬទេ? ៤) សម័យឥឡូវ បើកាលណាមានកើតការរង្កៀស រវាងប្រទេសនឹងប្រទេស តើគេត្រូវនិយមធ្វើអ្វី?

# ភាគអត្ថបទ
## សតវត្សរ៍ទី ២០ - អត្ថបទបករប្រែ

# ចចក និង ពពែ

ពីព្រេងនាយ ចាស់បុរាណដំណាលថា មានពពែច្រើនអនេក អាស្រ័យនៅក្នុងគុហាមួយ ក្នុងព្រៃហិមពាន្ត ។ បណ្ដាពពែទាំងនោះ មានមេពពែមួយ ឈ្មោះមេណ្ឌមាតា មានបញ្ញាឆ្លាតណាស់ ព្រមទាំងចេះកិច្ចកលឧបាយផង ។

មិនឆ្ងាយពីលំនៅពពែទាំងនោះប៉ុន្មាន មានគុហាមួយទៀត ជាកន្លែងនៅនៃចចកឈ្មោះ បូតិមំសៈ នឹងចចកញីជាភរិយា ឈ្មោះនាងវេណិយា ។ ចចកឈ្មោលញី តែងប្រើកលល្បិច ហើយចាប់ពពែស៊ីអស់ជាច្រើន ។

ថ្ងៃមួយ បូតិមំសៈ មានបំណងចង់ស៊ីនាងមេណ្ឌមាតាទៀត ទើបហៅភរិយាមក ហើយប្រាប់ថាៈ

— ប្អូនទៅទាក់ទងស្និទ្ធស្នាលធ្វើជាមិត្រនឹងមេណ្ឌមាតា ។ កាលណាការស្និទ្ធស្នាលកើតមានហើយ មងពុតធ្វើជាឈឺ រួចអូនទៅប្រាប់មេណ្ឌមាតាថា ឥឡូវប្ដីខ្ញុំស្លាប់ហើយ ខ្ញុំទៅជាអនាថា គ្មានញាតិសន្ដានឯណាគ្រាន់ជាទីពឹងទេ ក្រៅតែពីសំឡាញ់ឯង សូមសំឡាញ់អញ្ជើញ

មក យើងទាំងពីរនាក់ទៅជាមួយគ្នា ដើម្បីជួយរៀបចំបូជាសពគាត់ផង ហើយប្អូនត្រូវនាំមេណ្ឌមាតាមក ចំណែកបងស្មុះគ្រោកឡើង សន្ទ្រប់ព្ទផក ហើយយើងនាំគ្នាអាស្រ័យជាអាហារយ៉ាងស្រួល ។

នាងវេណិយាទទួលធ្វើតាមសេចក្ដីបង្គាប់បូតិមំសៈ ។ លុះសេចក្ដីស្និទ្ធស្នាលរាប់អានមានបរិបូណ៌ហើយ ទើបចចកញៀននិយាយប្រាប់មេណ្ឌមាតា តាមមធ្យោបាយ បូតិមំសៈខាងលើ ។

មេណ្ឌមាតាស្ដាប់ហើយឆ្លើយថា :

– ពពែទាំងឡាយជាសាច់ញាតិខ្ញុំ ត្រូវប្ដីនាងស៊ីអស់ច្រើនណាស់ហើយ ខ្ញុំខ្លាចណាស់ ខ្ញុំមិនហ៊ានទៅទេ ។

វេណិយានិយាយអង្វរទៀតថា :

– ប្អូនសំឡាញ់កុំខ្លាច គាត់ស្លាប់ហើយ គាត់នឹងអាចធ្វើអ្វីយើងកើត!

ជាតែប៉ុណ្ណោះហើយ វេណិយា នាំមេណ្ឌមាតាទៅ ។ បូតិមំសៈដែលកំពុងសំងំពួន លុះឮស្នូរជើងដើរពីចម្ងាយ នឹកអរព្រួចថាៈមេណ្ឌមាតាមកហើយតើ! រួចងើបក្បាលបង្អើបលួចមើល ។

ពពែញីក្អែកវៃ ក្រឡេកទៅឃើញក្បាលប្ដីមិនសះ ងើបឡើង ទើបស្រែកថា :

— តាហាវគម្រក់នេះ បញ្ឆោតអញទេតើ វាដេកពុតធ្វើជាស្លាប់ ឲ្យប្រពន្ធវាមកហៅអញ ។

រួចពពែញីក៏រត់ត្រឡប់ទៅទីលំនៅអាត្មាវិញ ។

នាងវេណិយា ឃាត់ថា :

— ទេ! សំឡាញ់ មិតមែនទេ! គាត់ពិតជាស្លាប់ហើយ តែក្អែក សំឡាញ់មើលប្រឡំទេ ។

ទោះបីចចកញីថាដូចម្ដេច ក៏មេណ្ឌាមាតាឈប់ជឿ បេះតែរត់ត្រឡប់ទៅវិញ ។

វេណិយាចូលមករកប្ដី ហើយពោលបន្ទោសជាអនេកប្បរិយាយ ។

គម្ពីរមង្គលត្ថទីបនី

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) គុហា ។ ២) អនាថា (អៈណាថា) ។ ៣) សព ។ ៤) អនេកប្ប-រិយាយ ។ ៥) ព្រហ្មទត្ត (ព្រហ្មៈទត្ត) ។

## ខ) ផែនការ

១) អត្ថបទនេះចែកជាប៉ុន្មានសង្កាត់?

២) តើសង្កាត់នីមួយ ៗ ពោលអំពីអ្វី?

## គ) អក្សរសិល្ប៍

១) អត្ថបទនេះអាចផ្ដល់នូវគតិប៉ុន្មានយ៉ាងដល់អ្នកអាន?

២) គតិនីមួយ ៗ មានន័យដូចម្ដេច?

## ឃ) វេយ្យាករណ៍

១) បណ្ដា (បណ្ដាពពែទាំងឡាយ): ហេតុអ្វីក៏គេសរសេរ «ណ្ដ» ?

២) សន្ដាន (ញាតិសន្ដាន): ហេតុអ្វីក៏គេមិនសរសេរ «ណ្ដ» ព្រោះគេអានមានសូរជាអក្សរ «ណ្ដ» ? ៣) ពាក្យជាសមានសព្ទ «ពុត» (បន្ទពុតធ្វើជាឈើ) ?

# ក្អែក នឹង ហង្ស

ពីព្រេងនាយ គេដំណាលថា: នៅក្នុងព្រៃហិមពាន្ត មានហង្សមាសមួយ ជារាជបក្សី ដែលមានព្រះរាជធីតាមួយព្រះអង្គ ប្រកបដោយព្រះរូបឆោមលោមពណ៌ដ៏ឆើតឆាយ ។ ស្ដេចហង្សនេះ បានទ្រង់ប្រទានពរដល់ព្រះរាជបុត្រីថា ឲ្យព្រះនាងធីតាអាចជ្រើសរកព្រះស្វាមីតាមគាប់ព្រះហឫទ័យព្រះនាងបាន ។

លុះព្រះរាជធីតាមានព្រះជន្មគ្រប់ការហើយ ព្រះវររាជបិតា ទ្រង់ប្រជុំអស់ពួកសកុណាទាំងឡាយ ក្នុងព្រៃហិមវន្ត ដើម្បីធ្វើពិធីស្វយម្ពរៈ ។

សត្វស្លាបទាំងឡាយផ្សេង ៗ មានក្អែកជាដើម បានមកកាន់ទីមហាសន្និបាតលើផ្ទៃផែនសិលាមួយដ៏ធំ ។ ស្ដេចសុវណ្ណហង្ស ទ្រង់ព្រះបញ្ជាឲ្យគេអញ្ជើញព្រះរាជធីតាស្ដេចយាងមក ហើយមានព្រះបន្ទូលត្រាស់ថា: «ចូរកូនស្រី ជ្រើសរើសព្រះស្វាមីតាមព្រះហឫទ័យកូនចុះ» ។

ព្រះរាជធីតា កាលក្រឡេកទតអស់ទាំងសកុណជាតិទាំងឡាយ ក៏បានទ្រង់យល់ក្អែកកំឡោះមួយ មានរោមត្រង់កពណ៌ដូចពេជ្រ កន្ទុយរោមដ៏វិចិត្រដោយពណ៌ជាអនេកប្បការ ហើយក្រាបបង្គំទូលព្រះវររាជបិតា

ថា: «ក្អែកនេះ ខ្ញុំម្ចាស់ពេញហឫទ័យណាស់ សូមឲ្យគេបានជាស្វាមីនៃខ្ញុំម្ចាស់ចុះ» ។

សត្វស្លាបនានា នាំគ្នាចូលទៅរកក្អែក ហើយសរសើរថា: «ម្នាលក្អែកជាសំឡាញ់ ព្រះរាជធីតាបានញុំាងសេចក្ដីគាប់ព្រះហឫទ័យ ឲ្យកើតមានក្នុងរូបអ្នកហើយ នេះគឺជាព្រេងវាសនារបស់អ្នកពីអតីតមក» ។

បានឮដូច្នោះ ក្អែកនឹកថា ថ្ងៃនេះ អញត្រូវសំដែងអានុភាពវិជ្ជាបង្ហាញចំពោះពួកសត្វស្លាបទាំងឡាយ ឲ្យបានឃើញជាក់ស្ដែងមួយ ។ គិតហើយ ក្អែកក៏បំបែកហរិទ្ធតប្ប: គឺលាត្រដាងស្លាបនាកណ្ដាលពួកបក្សីទាំងពួង ហើយប្រារព្ធរាំឡើង ព្រោះតែសេចក្ដីត្រេកអរក្រៃពេក ។

បលនានេះធ្វើឲ្យឃើញថាក្អែក ជាសត្វគ្មានការរម្យទម ដ្បិតអាការទាំងប៉ុន្មានរបស់ខ្លួន បង្ហាញឲ្យគេឃើញឥតមានសល់ ។

ខណៈនោះ ស្ដេចហង្សមាស អៀនអន់ព្រះរាជហឫទ័យពេក ទ្រង់ក៏ប្រកាសចំពោះពពួកសត្វស្លាបទាំងឡាយថា: "ក្អែកនេះ ជាសត្វគ្មានហរិទ្ធតប្ប: ខ្ញុំមិនអាចប្រទានព្រះរាជធីតាខ្ញុំ ដល់សត្វដែលមានសភាពយ៉ាងដូច្នេះឡើយ" ។

រួចទ្រង់ប្រកាសបង្ខិលព្រះរាជធីតា ប្រទានចំពោះក្មួយនៃព្រះអង្គវិញ ។ ពាំណែកក្អែក កាលបើត្រឡប់ជាមិនបានព្រះរាជធីតាទៅវិញ មានសេចក្ដីអៀនខ្មាសខ្លាំង ក៏ស្ទុះហើររត់បាត់ទៅ ។

ខុទ្ទកនិបាត

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ពរ ។ ២) សកុណា ។ ៣) បក្សី ។ ៤) ស្វយម្ពរៈ (ស្វៈយុំពរ ។ ៥) សុវណ្ណហង្ស (សុវ៉ាន់ណៈហង្ស ។ ៦) អនេកប្បការ ។ ៧) ហិរិឱតប្បៈ (ហិរិឱតាប់ប៉ៈ) ។ ៨) ប្រារម្ភ ។

## ខ) ផែនការ

១) កំណាព្យបទនេះ មានប៉ុន្មានសង្កាត់? ។ ២) ចូរឲ្យនាមដល់សង្កាត់នីមួយៗ ។

## គ) សំនួរ

១) ព្រះរាជធីតានៃសុវណ្ណហង្ស ហេតុអ្វីក៏ទ្រង់សព្វព្រះហឫទ័យនឹងក្អែក? ។ ២) សុវណ្ណហង្សដែលឈប់ប្រទានព្រះរាជធីតាដល់ក្អែក ព្រោះហេតុអ្វី? ។ ៣) ដោយប្រការម្ដេច បានជាក្អែកស្ទុះហើររត់បាត់មុនសត្វស្លាបដទៃ? ។

## ឃ) អត្ថរសទូទៅ

រឿងក្មេកនឹងហាន្សនេះ ផ្តល់ជាគតិដូចម្តេចខ្លះ ដល់អ្នកអានទាំងឡាយ?

## ង) វេយ្យាករណ៍

១) ចូររកពាក្យជាវេវចនៈនៃ «ស្វាមី» – «សិលា» ។

២) ចូរពប់នាមសត្វខ្លះ និងបក្សីខ្លះ មកមើល ។

---

# មិត្តវិន្ទក

នៅក្រុងពារាណសី មានកុដុម្ពិកម្នាក់ មានទ្រព្យ៤០សិបកោដិ ហើយមានកូនប្រុសមួយឈ្មោះ មិត្តវិន្ទក ដែលជាកុមារគ្មានសណ្តាប់ធ្នាប់ ចិត្តព្រហើនកោងកាច ។

ខាងក្រោយកាលកិរិយានៃបិតាទៅ សេដ្ឋីបុត្រពោលប្រាប់ម្តាយថា:

– បពិត្រលោកម៉ែ ខ្ញុំចង់ទៅជួញប្រែនឹងគេតាមសំពៅ ។

ឮដូច្នោះ ម្តាយនិយាយឃាត់ថា:

— ម្ដាលបាជាទីសំឡាញ់ ឯងជាកូនតូចតែមួយ កុំទៅជួញធ្វើអ្វី ទ្រព្យសម្បត្តិយើងក្នុងផ្ទះច្រើនណាស់ ចាយរាយមិនអស់ទេ ។ ម្យ៉ាងទៀត ក្នុងសមុទ្រ មានទោសច្រើនប្រការណាស់កូន ។

មាណពនោះ ទោះបីម្ដាយឃាត់យ៉ាងណាក៏មិនស្ដាប់ ជំនះតែទៅ ។ ម្ដាយស្ទុះឃាំងផ្លូវ ចៅមាណពរុញម្ដាយដួល ហើយរត់ទៅចុះសំពៅដើម្បីជួញជាមួយនឹងគេ ។

សំពៅដែលបើកទៅបានប្រាំពីរថ្ងៃ ស្រាប់តែគៀងនៅនឹងថ្កល់ នា-កណ្ដាលសាគរ ។ មនុស្សទាំងឡាយនាំគ្នារំពឹងពិចារណាថា: « ក្នុងសំពៅយើង ទៀងតែមានមនុស្សកាឡកិណ្ណីដោយពិត » ។ លុះប្រឹក្សាគ្នាដូច្នោះហើយ គេធ្វើស្លាកឲ្យពល់គ្នាចាប់ ឯស្លាកអកុសល បានធ្លាក់ទៅលើមិត្តវិន្ទុក អស់វារៈបីដង ។

គ្រានោះ មហាជនក្នុងសំពៅ ធ្វើក្បូនមួយដាក់មិត្តវិន្ទុកលើនោះ ហើយបណ្ដែតពោងពាយទៅ ។ មនុស្សកាឡកិណ្ណីនេះ កាលអណ្ដែតតាមខ្សែទឹកទៅ បានដល់កូនកោះមួយ ហើយប្រទះនឹងវាំងមួយមានទ្វារបួន ។ មិត្តវិន្ទុក បានឃើញសត្វនរកម្នាក់ កំពុងទូលខុរចក្រឮដក្បាល យំទួញបណ្ដើរ ដើរបណ្ដើរ ។

ខណៈនោះ ខុរចក្រដែលនៅលើក្បាលសត្វនរក ត្រឡប់មាន សភាព ដូចជាផ្កាឈូកកើតឡើងប្រាកដដល់ភ្នែកមិត្តវិន្ទុក ឈាមដែល កំពុងហូរចេញពីក្បាល ហាក់ដូចជាម្សៅខ្លឹមចន្ទន៍ សូរសម្រែកយំ ដូច ជាចម្រៀងដ៏ពីរោះ ៗ អកុតញ្ញុមាណព ដើរចូលទៅជិតហើយនិយាយ សរសើរថា:

បពិត្របុរសដ៏ប្រសើរអើយ អ្នកមានរាសនាល្អម៉្លេះទេ ឥឡូវអ្នក ប្រដាប់គាក់តែងកាយយ៉ាងនេះ អស់កាលដ៏យូរហើយ សូមឲ្យផ្កាឈូក នុះ មកខ្ញុំប្រដាប់កាយម្ដងផង ៗ

សត្វនរកនឹកថា: អកុសលកម្មរបស់អញ ប្រហែលអស់ត្រឹមពេល នេះហើយ បុរសនេះប្រហែលជាបានធ្វើបាបដល់ឪពុកម្ដាយដូចជាអញ ដែរ បានជាគាត់ស្មានខុសដូច្នេះ ៗ នឹកតែម៉្លោះហើយ សត្វនរកក៏ បោះខុរចក្រ មកលើក្បាលមិត្តវិន្ទុក ៗ វេលានោះ មិត្តវិន្ទុក កាលបើ ដឹងជាខុរចក្រវិញ ទើបស្រែកប្រាប់ថា:

— សូមអ្នកត្រឡប់យកខុរចក្ររបស់អ្នកទៅវិញចុះ ៗ

ប៉ុន្តែសត្វនរក ស្រាប់តែអន្តរធានពីទីនោះមួយរំពេច ។ ចំណែកមិត្ត

វិន្ទុក ត្រូវទទួលរងទុក្ខវេទនារហូតតទៅ ។

អដ្ឋកថាធម្មបទ។

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ពារាណសី ។ ២) កុដុម្ពិក៍ ។ ៣) កាលកិរិយា ។ ៤) មាណព ។ ៥) កាឡកណ្ណី ។ ៦) សត្វនរក ។ ៧) ខុរចក្រ ។

## ខ) ផែនការ

១) អត្ថបទនេះ អាចចែកបានជាប៉ុន្មានសង្កាត់?

២) ចូរឲ្យនាមដល់សង្កាត់នីមួយ ៗ ។

## គ) សំនួរ

១) មិត្តវិន្ទុក បានធ្វើអំពើត្គាំត្គងអ្វីដល់ម្ដាយ? ។ ២) ហេតុដូចម្ដេចបានជា មិត្តវិន្ទុក ក្លាយទៅជាក្មេងកាចសាហាវដូច្នេះ? ។ ៣) អ្វីធ្វើឲ្យសំពៅដែលមិត្តវិន្ទុកជិះ មិនអាចបើកទៅមុខបាន? ៤) ហេតុអ្វីក៏មិត្តវិន្ទុក ឃើញខុរចក្រដូចជាផ្កាឈូក?

## ឃ) អត្ថរសទូទៅ

អត្ថបទនេះ នឹងផ្តល់នូវគតិដល់អ្នកអានយ៉ាងណា ?

## ង) វេយ្យាករណ៍

១) ចូររកពាក្យជាសន្តាននឹង «ប្រុស» - «បណ្តើរ» ។ ២) ចូររកពាក្យផ្ទុយនឹង «ញាប» - «បាត់» - «យំ» ។

---

# សត្វចាប និងព្រាន

កន្លងកាលកន្លងទៅហើយ ព្រះពោធិសត្វជាម្ចាស់យើង បានយោនយកកំណើតជាចាប មានចាបដទៃច្រើនពាន់ហោមរោមជាបរិវារ ហើយមានព្រៃមួយកន្លែងជាទីសំណាក់អាស្រ័យ ។

គ្រាកាលនោះ មានព្រានចាបម្នាក់ ត្រាច់ទៅក្នុងព្រៃ ហើយបានប្រទះកន្លែងដែលចាបទាំងនោះអាស្រ័យនៅ ។ ព្រានបានកំណត់កន្លែងនោះទុក ហើយពេលក្រោយ ក៏យកសំណាញ់ទៅបោះគ្របពីលើ ក្តោបដោយសំណាញ់ខាងក្រោម ចាប់ចាបទាំងឡាយដាក់ទ្រុង នាំយកទៅកាន់ភូមិ រួចលក់យកតម្លៃ ដើម្បីចិញ្ចឹមជីវិតតរៀងទៅ ។

ថ្ងៃមួយ ស្ដេចចាបមានវាចាទៅកាន់ចាបដាបរិវារទាំងឡាយថា៖

— អាដែងព្រានសត្វស្លាបនេះ បានធ្វើឲ្យវិនាសញាតិសន្ដានយើងអស់ជាច្រើន អ្នកទាំងឡាយត្រូវធ្វើតាមឧបាយយើង ទើបអាចរួចអំពីសេចក្ដីអន្តរាយនេះបាន ៗ ដូច្នេះ ចាប់ពីថ្ងៃនេះទៅ អ្នកពល់គ្នា កាលបើមានសំណាញ់ធ្លាក់គ្របពីលើហើយ ត្រូវយកក្បាលគ្រប់គ្នាស៊កតាមរន្ធសំណាញ់ដោយចិត្តស្ម័គ្រ ហើយហើរឡើងស្រុះគ្នា ទូលសំណាញ់នេះយកទៅបំពាក់លើគុម្ពបន្ទាមួយ រួចគ្នាយើងត្រូវស្រុះហើររត់ចេញតាមកាគខាងក្រោមនៃសំណាញ់ ៗ

ចាបទាំងឡាយទទួលស្ដាប់នូវឱវាទដ៏ប្រសើរនេះ ដោយសេចក្ដីគោរព ៗ

កន្លងថ្ងៃបន្ទាប់មក ព្រានសត្វស្លាប យកសំណាញ់ទៅបោះគ្របពីលើទៀត ៗ ចាបទាំងឡាយនាំគ្នាធ្វើតាមពាក្យដំបូន្មានព្រះពោធិសត្វ ហើយហើរនាំយកសំណាញ់ទៅបំពាក់លើគុម្ពបន្ទាមួយ រួចនាំគ្នាហើររត់ចេញតាមកាគខាងក្រោមអស់រលីង ៗ ចំណែកចៅព្រាន អាល័យតែដោះ

សំណាញ់ដែលដំពាក់ព័ទ្ធពន្ធដោយបន្ទា ពេលវិកាលក៏មកដល់ ហើយត្រូវតែត្រឡប់មកផ្ទះដោយដៃទទេ ។

ចាប់តាំងពីព្រឹកថ្ងៃស្អែកតទៅ ពួកចាបតែងតែប្រកាន់ទុក នូវលទ្ធិដ៏ប្រពៃនេះ ។ ឯនាយព្រានសត្វស្ទាប ឈប់ខានបានចាបយកទៅលក់ដូចពីពេលមុនៗទៀត ។

ខុទ្ទកនិបាត

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ពោធិសត្វ ។ ២) ឧបាយ ។ ៣) ឆ្លាំង ។ ៤) ពេលវិកាល ។ ៥) លទ្ធិ (ឡាត់ធិ) ។

## ខ) ផែនការ

ចូររកសង្កាត់កន្សែអត្ថបទនេះ តើមានប៉ុន្មាន? ហើយចូរឲ្យនាមដល់សង្កាត់នីមួយៗផង ។

## គ) សំនួរ

១) ហេតុដូចម្ដេច បានជាស្ដេចចាបពោលថា: ត្រូវឲ្យមានចិត្តស្រុះស្រួល?

២) ហេតុអ្វីក៏ពួកចាបជាប់សំណាញ់ មិននាំគ្នាហើរទៅទាន់ឡើ?

៣) ដោយប្រការម្ដេច ពួកចាបហើរនាំសំណាញ់ទៅបំពាក់លើគុម្ពព្រៃមានបន្លា?

## ឃ) អត្ថរសទូទៅ

កាលបើយើងអានអត្ថបទនេះ តើយើងអាចទាញយកនូវគតិដូចម្ដេច?

## ង) វេយ្យាករណ៍

១) ចូររកពាក្យជាសមានសព្ទនឹង «គ្រា» (គ្រាកាលនោះ) ។ ២) ចូររកពាក្យជាវេវចនៈនឹង «ទីពឹង» ។ ៣) ចូរចង្អុលប្រាប់នូវកិរិយាវិសេសដែលមានក្នុងប្រយោគ «ចាបទាំងឡាយនាំគ្នាធ្វើតាមពាក្យដំបូន្មានព្រះពោធិសត្វ . . . . . ទាន់ក្រោមអស់រលីង» ។

---

## ឱវាទប្រាំប្រការ

លោក នួរេទឌីន-អាលី មានឋានៈជាអគ្គមហាសេនានៃព្រះចៅកាលីហ្វ ក្រុងបាស្វ៉ា ។ ខាងក្រោយដែលលោកបានបំពេញមុខងារនៃអាត្មាប្រកបដោយសុចរិតនឹងយុត្តិធម៌ បំពោះជាតិសាសនា នឹង ព្រះមហាក្សត្រ លោកបានដល់នូវជម្ងឺដ៏ទម្ងន់ ដែលជាហេតុនាំឲ្យលោកអស់សង្ឃឹម មជានឹងមានជីវិតតទៅ រួចលោកក៏ហៅកូនមកឲ្យដំបូន្មាន ដូចមានក្នុងអត្ថបទនេះ ។

ខណៈនោះ លោកទូវេទខិន-គាលី កាន់តែខ្សោយកម្លាំងជុនជាបចុះបន្តិចម្តងៗ រហូតដល់ក៏កបាត់ស្មារតីសូន្យឈឹង ។ ប៉ុន្តែមួយស្របក់ក្រោយមក លោកលោភ្ញាក់ខ្លួនមានស្មារតីឡើងវិញ ទើបលោកផ្ញៀតឲ្យឪវាទជាទីបំផុត ដល់កូនសំឡាញ់ថា :

– ប្រុសស្ងួនឪពុក នៅទីបំផុតនេះ ឪពុកឲ្យឪវាទប្រាំយ៉ាងដល់កូន ដូចសេចក្តីខាងក្រោយនេះ ៖

„(១) កុំកប់ប្រសព្វទឹងមនុស្សគ្រប់បែបទាំងអស់ ។ មធ្យោបាយដើម្បីនឹង
„បិញ្ចឹមជីវិតដោយកេ្យមកក្រាន្តនោះ គឺខ្លួនត្រូវទីពឹងខ្លួនដោយពេញបន្ទុក
„ហើយបើមានកិច្ចការអ្វីៗ មិនត្រូវអើលមាត់ផ្សាយប្រាប់គ្នាដោយងាយៗ
„ឡើយ ។

„(២) កុំតាំងអាជ្ញាជាក់កម្រិតបង្ខិតបង្ខំបៀតបៀនគេទាំងអំណាច ព្រោះកាល
„បើអ្នកធ្វើដូច្នេះ មនុស្សទាំងពួងនឹងរកពឿងក្បត់ចំពោះអ្នកវិញពុំខាន អ្នក
„ត្រូវទុកមនុស្សទាំងអស់ដូចជាម្ចាស់បំណុល ដែលអ្នកគួរតែមានសេចក្តី
„យោគយល់ សេចក្តីអាណិតអាសូរនឹងសេចក្តីសន្តោសប្រោសប្រណី ។

„(៣) កាលបើមានគេតិះដៀលប្រទេចផ្កាសាអ្នកៗ កុំតបឲ្យសោះ ដ្បិតមាន

« សុភាសិតថា: «គេអាចរួចអំពីគ្រោះថ្នាក់បាន ដោយបិទវចីទ្វារ» នេះឯង
« ហើយជាកិច្ចយ៉ាងឯកដែលអ្នកត្រូវប្រព្រឹត្តកាន់តាម រឿងនេះអ្នកបានចេះ
« ដឹងស្រាប់ហើយ ដូចមានកវីម្នាក់និយាយថា: «សេចក្ដីស្ងៀមជាអលង្ការ
« ទឹងជាគ្រឿងការពារជីវិត» ពេលនិយាយម្ដងៗ កុំប្រើសំដីឲ្យដូចជាក្លៀង
« លាយព្យុះ ដែលបំផ្លាញរបស់គ្រប់ដំពូក គេមិនដែលក្ដៅក្រហាយស្ដាយ
« ក្រោយ ព្រោះតែស្ងៀមទេ ។

«៤) កុំផឹកទឹកស្រវឹង ព្រោះទឹកនេះ ជាដើមចមនៃអំពើទុច្ចរិតទាំងពួង ។

«៥) ត្រូវចេះលៃលកសំចៃទ្រព្យសម្បត្តិ បើអ្នកអាចរក្សាទ្រព្យទុកបាន កុំឲ្យ
« ខូចវិនាសអសារឥតការ ទ្រព្យនោះនឹងបានជាប្រយោជន៍ ក្នុងពេលដែល
« អ្នកមានកិច្ចធុរៈ ៗ ម្យ៉ាងទៀត មិនត្រូវធ្វើខ្លួនឲ្យជាអ្នកកំណាញ់ក្រៃ
« តម្រាទេ ត្រូវតែចែករំលែកចាយវាយ ទោះបីតិចច្រើន តាមធនធាន
« របស់យើង កាលបើធ្វើយ៉ាងនេះ អ្នកនឹងមានមិត្រច្រើន ប៉ុន្តែ ប្រសិន
« បើអ្នកមានសម្បត្តិច្រើន ហើយយកទៅប្រើខុសទំនងនោះ អ្នកនឹងបែរ
« ទៅជាល្ងើយ នាំឲ្យទំនាស់ខូចប្រយោជន៍ទៅវិញ គឺមនុស្សទាំងអស់នឹង
« ស្អប់ខ្ពើមអ្នក ហើយគេនឹងបោះបង់អ្នកចោលលែងរាប់អាន » ។

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ស្មារតី ។ ២) ក្រេមក្សាន្ត ។ ៣) ក្សត់ ។ ៤) សន្តោស ។ ៥) វប្បីធារ ។ ៦) កិច្ចយ៉ាងឯក ។ ៧) ទុច្ចរិត ។ ៨) អ្នកនឹងបែរទៅជាឈ្លើយ ។

## ខ) សំនួរ

១) ហេតុដូចម្តេច បានជាលោកនូវេទឌិន-អាលី មិនឲ្យទៅទងដល់កូន នៅពេលដែលលោកនៅមានកំឡាំង ទុកចាំដល់ជិតផុតដង្ហើម ទើបហៅកូនមកឲ្យដំបូន្មាន ? ២) ហេតុអ្វីក៏ត្រូវទុកមនុស្សទាំងអស់ដូចជាម្ចាស់បំណុល ? ៣) តើជាការណ៍ពិតយ៉ាងដូច្នេះឬ ដែលលោកនូវេទឌិន-អាលីពោលថា: «គេមិនដែលក្តៅក្រហាយស្តាយក្រោយ ព្រោះតែស្ងៀមទេ» ? ៤) ព្រោះហេតុអ្វី បានជាថាទឹកស្រវឹង ទុកជាដើមចមនៃអំពើទុច្ចរិតទាំងពួង ?

## គ) វេយ្យាករណ៍

១) ចូរអធិប្បាយពន្យល់ពាក្យ «បង្ខំ» នឹង «ខំ» តើមានន័យផ្សេងគ្នាដូចម្តេច? ២) ចូររកពាក្យជាវេវចនៈ នឹង «ធុរៈ»—«ធនធាន» ។ ៣) ចូររកពាក្យជាសមានសព្ទនឹង «ឈ្លើយ» ។

## ឃ) និពន្ធសេចក្ដី

ចូរអត្ថាធិប្បាយនូវភាសិតថា: «គេអាចរួចអំពីគ្រោះថ្នាក់បាន ដោយ បរិវប្បីទារ» ហើយសូមឲ្យឧទាហរណ៍ខ្លះមកជាគ្រឿងអាងផង ។

---

# សត្វលា និងនាយកប្បកៈ

កាលពីព្រេងនាយ នៅឯប្រទេសក្លិង្គ ក្នុងនគរពារាណសី មានពាណិជម្នាក់ឈ្មោះកប្បកៈ អ្នកនេះមានលាមួយ ដែលអាចនាំទំនិញមានទម្ងន់មួយកុម្ភៈបាន ហើយដើរបានប្រាំពីរយោជន៍ក្នុងមួយថ្ងៃ ។

ថ្ងៃមួយនាយពាណិជ បានផ្ទុកទំនិញលើសត្វលា បរទៅឯនគរតក្កសិលា ដើម្បីជួញប្រែ ។ លុះដល់ហើយ នាយកប្បកៈ បានដោះលាលែងឲ្យទៅស៊ីស្មៅ ។ លាបានដើរទៅក្បែរគូមួយ ហើយបានជួបនឹងលាញីមួយកំពុងនៅស៊ីស្មៅត្រង់ទីនោះ ។ លាញីនេះ បានធ្វើបដិសណ្ឋារកិច្ចយ៉ាងពក់ទាក់ ហើយសួរថា:

— អ្នកបង់មកពីស្រុកណា ?

លាឈ្មោលប្រាប់ថា:

— ខ្ញុំមកពីនគរពារាណសី ។

ខាងក្រោយការសាកសួរ លាទាំងពីរក៏បវេចាកាន់គ្នាទៅវិញទៅមក អំពីរឿងផ្សេង ៗ ។ ក្នុងទីបំផុត បតុបាទឈ្មោលញី កើតមានក្តីប្រតិព័ទ្ធ បំពោះគ្នានឹងគ្នា ។

ឯនាយកប្បុក: កាលបើលក់ទំនិញអស់ហើយ ក៏ទៅហៅលាឈ្មោលថា:

— ម្នាលលាមក! យើងនឹងត្រឡប់ទៅពាណិជ្ជសីវិញ ។

លាឆ្លើយប្រកែកថា:

— សូមលោកអញ្ជើញទៅតែម្នាក់ឯងចុះ ខ្ញុំមិនទៅទេ ។

នាយពាណិជអង្វរករច្រើនដង លានៅតែឆ្លើយបដិសេធ ៗ ម្ចាស់លានឹកឆ្ងល់ពេក ងាកមើលឆ្វេងស្តាំ ស្រាប់តែបានឃើញលាញីមួយនៅក្បែរនោះ ។ នាយពាណិជសន្និដ្ឋានថា លានេះពិតជាជាប់ចិត្តក្នុងលាញីនុះជាមិនខាន ។

នាយកប្បុក:និយាយលួងលោមថា:

– ម្នាលលាដ៏ជាទីស្រឡាញ់ ឲ្យតែឯងព្រមសុខចិត្តត្រឡប់ទៅផ្ទះវិញចុះ អញនឹងរកនារីដើម្បីមុខដូចស័ន្ធ សណ្ឋានកាយល្អស្អាតយកមកធ្វើជាប្រពន្ធលាឯង ។

បានឮដូច្នោះ លាមានចិត្តត្រេកអរ ទើបដាច់ចិត្តព្រមត្រឡប់ទៅនគរវិញ ។

លុះបានទៅដល់ផ្ទះហើយ នាយកប្បកៈធ្វើព្រងើយ ពុំនាំពាននីរកលាញីមកឲ្យធ្វើជាប្រពន្ធលាឈ្មោលឡើយ ។

ដោយអត់ទ្រាំតទៅទៀតពុំបាន ទើបលាសួរថា:

– បពិត្រលោកនាយ ! ដូចម្ដេចទៅ ពាក្យសន្យារបស់លោក?

នាយកប្បកៈឆ្លើយប្រាប់ថា:

– ពាក្យសន្យា អញមិនភ្លេចទេ ប៉ុន្តែអាហារសម្រាប់ភរិយា ឬកូនរបស់ឯង បើកាលណាមាននោះ អញមិនគោរពដឹងទេ អញត្រូវប្រគល់ចំពោះតែរូបឯងម្នាក់ប៉ុណ្ណោះ ។

លាពាល់គំនិត ព្រោះហួសហើយ ក៏នៅស្ងៀមរហូតទៅ ។

អដ្ឋកថាធម្មបទ

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) កុម្ភៈ ។ ២) តក្កសិលា (គាក់កាក់សិលា) ។ ៣) គូ ។ ៤) បដិសណ្ឋារកិច្ច ។ ៥) ធ្វើយបដិសេធ ។ ៦) សន្និដ្ឋាន ។ ៧) ស័ន្ធ ។ ៨) ពុំនាំពារ ។

## ខ) ផែនការ

ចូរកេសង្កាត់កន្លែងអត្ថបទនេះ តើមានប៉ុន្មាន ហើយចូរឲ្យនាមដល់សង្កាត់នីមួយ ៗ ។

## គ) សំនួរ

១) ហេតុដូចម្ដេច បានជាម្ចាស់លាទឹកធ្លល់? ២) សេចក្ដីត្រង់ណា ដែលបង្ហាញឲ្យយល់ថា ការសន្និដ្ឋាននៃម្ចាស់លា ពិតជាត្រូវ? ។ ៣) ត្រង់ដែលនាយកបង្រក: ពោលថាមិនត្រូវការដឹង អំពីអាហារសម្រាប់ការយានីង់គូនណា សឲ្យឃើញថាប្រទេសនោះមានទេសភាពយ៉ាងណា?

## ឃ) អក្សរសទូទៅ

**និទាននេះ** អាចនឹងផ្ដល់នូវគតិយ៉ាងដូចម្ដេច ដល់អ្នកអានទាំងឡាយ?

## ង) វេយ្យាករណ៍

ចូរអធិប្បាយពន្យល់អំពីពាក្យ "នុ៎ះ" និង "នោះ" តើមានសេចក្ដីផ្សេងគ្នាយ៉ាងណា ?

---

## នន្ទបុរស

មានតាព្រាហ្មណ៍ម្នាក់ បានយកទាសីរបស់ខ្លួនដែលនៅក្មេង ធ្វើជាប្រពន្ធ ។ ខាងក្រោយដែលបានកូនប្រុសមួយ គាត់ក៏អនិច្ចកម្មទៅ ។ កន្លងពីពេលនោះមក មិនបានប៉ុន្មានឆ្នាំ មាតានិយាយប្រាប់បុត្រថា:

– ម្នាលបា ! បិតាអ្នកបាននាំទាសៈឈ្មោះនន្ទនេះ ទៅកប់ទ្រព្យលាក់ក្នុងព្រៃជាមួយផង ចូរបាប្រាប់នន្ទឲ្យទៅបង្ហាញកន្លែង ហើយគាស់យកមក ។

ថ្ងៃមួយ កុមារនោះសួរនន្ទថា:

– លោកតូ ! បិតាខ្ញុំមានបើកប់ទ្រព្យទុកនៅឯណាខ្លះដែរឬ ?

នន្ទឆ្លើយថា:

– បពិត្រចៅហ្វាយ ! កំណប់ទ្រព្យនោះមាននៅក្នុងព្រៃរហោស្ថានឯណោះ ។

កុមារប្រាប់ថា:

— បើដូច្នេះ លោកតាជូនខ្ញុំទៅគាស់យកបន្តិច ។

មាណពកាន់ចបនឹងកញ្ជើ ដើរទៅកាន់ទីធ្លាន ។ លុះបានដល់ហើយ កុមារសួរនន្ទថា:

— ទ្រព្យនោះ បិតាខ្ញុំកប់ទុកត្រង់កន្លែងណា ?

ខាងក្រោយដែលបានដើរទៅឈរលើកន្លែងកំណប់ នន្ទស្រាប់តែមានមានះកើតឡើង ហើយជេរកុមារថា:

— ម្នាលកូនទាសីចង្រៃ ទ្រព្យរបស់ឯងនឹងមានមកពីឯណា?

កុមារនោះធ្វើដូចជាមិនឮ នូវសំដីផ្សេងៗរបស់នន្ទ ហើយពោលថា:

— ណ្ហើយលោកតា! បើរកមិនឃើញទេ យើងត្រូវត្រឡប់ទៅផ្ទះវិញៗ

កន្លងទៅបានពីរ-បីថ្ងៃ កូនតាព្រាហ្មណ៍ នាំនន្ទទៅម្ដងទៀត ។ នន្ទនៅតែជេរដូចកាលមុនដដែល ខាងក្រោយដែលគាត់បានទៅឈរពីលើកំណប់ ។ ចំណែកកុមារខំអត់សង្កត់ចិត្ត ឥតបានពោលតបនឹងផ្សេងៗនៃនន្ទឡើយ ហើយគ្រាន់តែនឹកថា:

— ពាសៈនេះជានឹងបង្ហាញគំណាប់ទ្រព្យដល់អញ លុះទៅដល់ព្រៃ ត្រឡប់ជាដេរអញវិញ អញមិនដឹងជាមានរឿងហេតុអ្វីនៅក្នុងទីនេះ តើនឹងមានអ្នកណាជាសំឡាញ់របស់ឪពុកអញឬទេ អញនឹងសួរដំណើរនេះ ប្រហែលជានឹងបានដឹង ។

លុះគិតដូច្នោះហើយ កុមារក៏ទៅកាន់សំណាក់លោកតាព្រឹទ្ធាចារ្យម្នាក់ នៅក្នុងភូមិជាមួយ ជំពបនូវរឿងហេតុខាងលើសព្វគ្រប់ ហើយសួរថា:

— បពិត្រលោកឪពុក! បើដូច្នេះ តើរឿងហ្នឹងនឹងមានប្រការដូចម្ដេចអេះ?

លោកតាព្រឹទ្ធាចារ្យប្រាប់ថា:

— ម្នាលកូន! កាលណានទូទៅឈរត្រង់កន្លែងណា ហើយដេរអ្នកទ្រព្យរបស់បិតាអ្នក កប់ត្រង់កន្លែងនោះហើយ ហេតុនេះ ពាសៈដេរអ្នកក្នុងវេលាណា អ្នកស្ទុះទៅទាញដៃគេចេញ រួចយកចបទៅជីកក្នុងវេលានោះ អ្នកនឹងបានឃើញទ្រព្យជាប្រាកដ ។

កុមារធ្វើតាមពាក្យទូន្មានរបស់លោកតាព្រឹទ្ធាចារ្យ ហើយបានប្រទះនូវគំណាប់ដូចសេចក្ដីប៉ុនប៉ង ។

ខុទ្ទកនិបាត

## ក) ពន្យល់ពាក្យនិងសំនួនវោហារ

១) ពាស: ។ ២) រហោស្ថាន ។ ៣) និធិដ្ឋាន ។ ៤) មាន: ។ ៥) សំដីផរុសវាចា ។ ៦) កំណាច់ ។

## ខ) សំនួរ

១) ហេតុអ្វីបានជានន្ទ កាលបានទៅឈរពីលើគន្លងកំណប់ហើយ ត្រឡប់ជាជេរកុមារវិញ? ។ ២) ហេតុដូចម្ដេច ក៏កុមារមិនអើពើនឹងពាក្យជេររបស់នន្ទ?

## គ) អត្ថសេចក្ដី

និទាននេះ អាចផ្ដល់ដល់អ្នកអានតាំងឡាយ នូវគតិយ៉ាងណា?

## ឃ) វេយ្យាករណ៍

កន្សោមប្រាប់វេយ្យាករណ៍៖ «ម្នាលបា-បពិត្រទៅហ្វាយ» មានឈ្មោះជាដូចម្ដេច?

# កុកនិងក្ដាម

គ្រាកាលនោះ មានមហាជាតស្រះមួយ ក្នុងកណ្ដាលព្រៃជ្រៅ ជាទីអាស្រ័យនៅនៃមច្ឆាទាំងឡាយ ។ ក្នុងនិទាឃរដូវ ទឹកក្នុងស្រះនោះរីងស្ងួតបង់អស់ នៅសល់តែប្រឡង់កណ្ដាល ។

មានមួយថ្ងៃ កុកមួយ កាលបើបានឃើញត្រីទាំងឡាយមានទឹកខ្វែងបង្អៀតបង្អល់ដូច្នោះ គិតថា: ‘‘អញនឹងប្រើឧបាយកលបញ្ឆោតត្រីទាំងនោះ ដើម្បីចឹកស៊ីឲ្យអស់,, រួចក៏ហើរទៅទំសំកុក នៅក្បែរស្រះនោះ ។

ខណៈនោះ ត្រីបានឃើញកុកទំសញ្ជប់សញ្ជឹង នៅក្បែរទឹក ទើបសួរថា:

— បពិត្រលោកម្ចាស់ លោកទំសញ្ជប់សញ្ជឹងក្នុងទីនេះ តើមានដំណើរការណ៍ដូចម្ដេច?

កុកឆ្លើយប្រាប់ថា :

— យើងសញ្ជប់សញ្ជឹង ដើម្បីគិតដល់វាសនាអាក្រក់នៃអ្នកទាំងឡាយ ។

— តើលោកម្ចាស់គិតដល់វាសនាអាក្រក់នៃយើងខ្ញុំ ដោយប្រការម្ដេច?

– ខ្ញុំគិតយ៉ាងដូច្នេះ «ទីគោចរក្នុងស្រះនេះ មានសភាពតឹងលំបាកផង ហើយនិទាឃរដូវក៏វែងឆ្ងាយផង បើយ៉ាងនេះ តើពួកត្រីទាំងឡាយនឹងប្រព្រឹត្តការចិញ្ចឹមជីវិត ដូចម្ដេចនឹងបានស្រួល?»

– បើយ៉ាងហ្នឹង តើយើងខ្ញុំនឹងត្រូវធ្វើដូចម្ដេច?

– បើអ្នកពលគ្នានឹងធ្វើតាមយើងៗ នឹងចិកពាំអ្នកមួយម្ដងៗយកទៅលែងទុកក្នុងមហាស្រះមួយ ដែលមានទឹកថ្លាត្រជាក់ ប្រកបដោយឈូកស ឈូកក្រហម ដុះពាសពេញ ។

– បពិត្រលោកម្ចាស់ តាំងពីបឋមកប្បមក យើងខ្ញុំមិនដែលឮកុកណា ចេះគិតដល់វាសនាត្រីទាំងឡាយម្ដងសោះ ក្រែងលោកម្ចាស់មានបំណងចង់អាស្រ័យយើងខ្ញុំទេដឹង? យើងខ្ញុំមិនជឿសំដីលោកទេ ។

– យើងមិនស៊ីទេ យើងចាស់ហើយ យើងកាន់សីលតែសព្វថ្ងៃ គិតតែប្រយោជន៍ទៅបរលោក ព្រោះពីក្មេង យើងធ្វើបាបច្រើនណាស់ បើអ្នកពលគ្នាមិនជឿថាមានស្រះ ចូរឲ្យត្រីណាមួយទៅជាមួយយើង ដើម្បីធ្វើសេចក្ដីបញ្ជាក់ ។

វេលានោះ ត្រីទាំងឡាយស្ដាប់បាន ក៏ប្រឹក្សាគ្នាថាៈ «ត្រីក្រាញ់អាចត្រាច់ទៅក្នុងទឹកផង លើគោកផងបាន ដូច្នេះគួរឲ្យត្រីក្រាញ់ទៅជាមួយនឹងកុកចុះ » ។

កុកពាំនាំត្រីក្រាញ់ ទៅដាក់លែងក្នុងស្រះមែន ហើយពាំនាំយកមកវិញ រួចដាក់លែងក្នុងសំណាក់ត្រីទាំងឡាយ ។ ត្រីក្រាញ់ក៏ពណ៌នានូវសម្បត្តិផ្សេងៗនៃស្រះនោះ ប្រាប់ដល់ពួកត្រីគ្នាវា ។ ត្រីទាំងឡាយ លុះបានឮពត៌មានដ៏ជាទីរីករាយ ក៏ចង់ទៅតែគ្រប់ៗគ្នា ហើយនិយាយប្រាប់កុកថាៈ

– បពិត្រលោកម្ចាស់ ការណ៍នេះប្រពៃមែនហើយ សូមលោកម្ចាស់នាំយើងខ្ញុំទៅចុះ ។

(នៅមានត)

## កុក នឹង ក្ដាម (តចប់)

កុកកំណាច ពាំនាំយកត្រីក្រាញ់ទៅមុនគេ ។ ម្ដងនេះ វាគ្រាន់តែហើរទៅក្បែរទឹងបង្ហាញឲ្យឃើញតែស្រះប៉ុណ្ណោះ រួចវានាំទៅទំពួនក្នុងដើមថ្កាន់ បញ្ចោកត្រីក្នុងប្រគាប ចឹកស៊ីសាច់អស់ ហើយទម្លាក់ចោលឆ្អឹងទៅក្រោមដើម ។ កុកស៊ីត្រីអស់គ្មានសល់មួយ ដោយប្រើឧបាយកលតែបែបយ៉ាងនេះ ។

ដំណាលថា នៅក្នុងស្រះនោះ មានក្តាមគ្រាន់មួយ ។ កុកប្រាថ្នានឹងស៊ីក្តាមទៀត ទើបនិយាយថា:

– នែបងក្តាម! បងឯងចង់ទៅក្នុងស្រះឯណោះនឹងគេដែរឬ? បើចង់ចូរចូលមក យើងនឹងនាំទៅឥឡូវ ។

ក្តាមសួរថា:

– លោកម្ចាស់ នឹងនាំខ្ញុំបាទទៅ ដោយប្រការម្តេច?

កុកប្រាប់ថា:

– យើងនឹងចឹកបងឯង ហើយពាំយកទៅ ។

– លោកម្ចាស់នាំខ្ញុំបាទតាមរបៀបខាងលើនេះ ខ្ញុំបាទមិនហ៊ានទៅជាមួយនឹងលោកម្ចាស់ទេ ប្រសិនបើលោកម្ចាស់ ឲ្យខ្ញុំបាទកៀបកលោកម្ចាស់ទើបខ្ញុំបាទទៅបាន ។

កុកចង់បញ្ឆោតក្តាម ហើយនឹកថា: «អាដែងក្តាមនេះ វាមិនដឹងជាអញយ៉ាងដូចម្តេចទេ រួចក៏ទទួលព្រមតាមបំណងក្តាម ។

ក្តាមគ្រាន់ ចាប់កៀបកកុកដោយដង្កៀប ដូចសណ្តាសជាងមាស ហើយប្រាប់ថា:

– សូមអញ្ជើញចុះលោកម្ចាស់ រួចហើយ !

កុកនាំយកក្តាមទៅបង្ហាញស្រះ ហើយហើរសំដៅដើមថ្កាន់ដូចមុនទៀត ៗ ឃើញអាការប្លែកដូច្នោះ ក្តាមសួរថា :

– បពិត្រលោកឪពុកធំ ស្រះនៅឯនុ៎ះ ហេតុអ្វីក៏លោកម្ចាស់ នាំខ្ញុំបាទមកឯនេះវិញ ?

កុកឆ្លើយប្រាប់ ដោយការកំហែងថា :

– ម្នាលអាក្តាមអបលក្ខណ៍ អញមិនមែនជាឪពុកធំអាឯងទេ ឯងជាកូនថៃប្អូនស្រីអញក៏មិនមែនដែរ អញមិនមែនជាខ្ញុំអាឯង សម្រាប់នាំអាមកដាក់ឲ្យរស់នៅបានស្រួលក្នុងស្រះឡើយ ម្នាលអាក្តាមកញ្ជោត ចូរអាឯងក្រឡេកមើលទៅគំនរឆ្អឹង ដែលមាននៅក្រោមដើមថ្កាន់នេះ អញស៊ីត្រីទាំងឡាយបែបយ៉ាងណា អញនឹងស៊ីអាឯងឥឡូវនេះបែបយ៉ាងនោះដែរ ៗ

ក្តាមគ្រោង ក៏ឆ្លើយគម្រាម តបទៅវិញថា :

– ម្នាលអាកុកអាប់ឥតប្រាជ្ញា! ត្រីទាំងឡាយនោះ បណ្តាយឲ្យអាកុកឯងស៊ីបាន ព្រោះវាសុទ្ធសឹងជាសត្វល្ងង់ឆោត បំណែកអញ មិនមែនឲ្យអាស៊ីបានទេ អញទៀងតែនឹងធ្វើអាឲ្យដល់នូវសេចក្តីវិនាស ជាមិនខាន

ដ្បិតអាជាសត្វល្ងង់ខ្លៅ មិនដឹងជាអញបញ្ឆោតអាឡើយ បើម៉្ងនឹងស្លាប់ត្រូវឲ្យស្លាប់ទាំងពីរនាក់ អញត្រូវកៀបផ្តាច់កអាឯង ហើយទម្លាក់ក្បាលអាទៅដី ក្នុងគ្រាឥឡូវនេះ ។

ពោលតែម្ល៉ោះហើយ ក្តាមក៏ចាប់កៀបកកុក យ៉ាងខ្លាំង ដោយជង្កៀប ដូចជាគេកៀបដោយសណ្ដាស ។

កុកឈឺពេក ហាមាត់បញ្ចេញទឹកភ្នែក ភ័យខ្លាចស្លាប់ ទើបអង្វរក្តាមថា:

– ឱ! លោកម្ចាស់ក្តាមអើយ ខ្ញុំបាទមិនហ៊ានអាស្រ័យលោកម្ចាស់ទេ លែងតែលោកម្ចាស់ទុកជីវិត ឲ្យខ្ញុំបាទផងចុះ ។

ក្តាមបង្គាប់ថា :

– បើអាឯងនាំអញចេញពីទីនេះ ហើយហើរនាំយកទៅលែងទុកឯក្នុងស្រះនុះ ទើបជីវិតអា នឹងអាចគង់នៅបាន ។

កុកក៏ហើរនាំយកក្តាមវិលទៅដាក់លើស្លឹកឈូកក្នុងស្រះ ។ ក្តាមបានដៃ កៀបកកុកយ៉ាងខ្លាំងអស្ចារ្យ ឧបមាដូចគេកាត់ទងឈូកនឹងកន្ត្រៃ រួបស្មុះរារបុះទឹកបាត់ ។

ខុទ្ទកនិបាត

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ដាតស្រះ (ដាត:ស្រះ) ។ ២) មច្ឆា (ម៉ាច់ឆា) ៖ ៣) និទាឃរដូវ (និទាឃ:រដូវ) ។ ៤) រាសនា ។ ៥) ទីគោចរ ។ ៦) បឋមកប្ប ។ ៧) បើម៉្ងនឹងស្លាប់ ។ ៨) សែនតែលោកម្ចាស់ទុកជីវិតឲ្យខ្ញុំបាទផងចុះ ។

## ខ) សំនួរ

១) កុកចាំប្រើទុច្ចាយគលល្បើអ្វី បើទឹកក្នុងស្រះនោះ រីងចង់អស់ហើយ ?

២) សំដីដោះសារបស់ត្រី អាចចាត់ទុកជាការមិនឆោតប៉ុន្មានដែរឬទេ ?

៣) ហេតុដូចម្ដេច បានជាកុកសុខចិត្ត បណ្ដោយឲ្យក្ដាមគ្រាន់កៀបកខ្លួន ?

## គ) ផែនការ

កថាវត្ថុបទនេះ តើមានប៉ុន្មានសង្កាត់ ? ចូរឲ្យឈ្មោះដល់សង្កាត់នីមួយៗ ?

## ឃ) អត្ថរសទូទៅ

និទាននេះ អាចផ្ដល់នូវគតិដល់អ្នកអានទាំងឡាយដូចម្ដេចខ្លះ ?

## ង) និពន្ធសេចក្ដី

១) ចូរអត្ថាធិប្បាយនូវភាសិតបូរាណ: «ពាក្យច្រើនកួត ចាញ់អាត្មា» ហើយចូរទាញយកឧទាហរណ៍មកជាគ្រឿងអាងផង ។

២) ចូរអត្ថាធិប្បាយខ្លីៗភាសិតបុរាណៈ«ចង់បុណ្យបានបាប ចង់ចេញចង់លាភ វង្វេងបាត់ធនទៅ» ព្រមទាំងទាញឧទាហរណ៍មកជាគ្រឿងអាងផង។

---

## ត្រលីងត្រលោង នឹង ស្វា

ពីព្រេងនាយ មានសត្វត្រលីងត្រលោងមួយ ធ្វើសំបុកនៅក្នុងព្រៃហិមពាន្ត ។ ខាងក្រោយមក ក្នុងរដូវមានភ្លៀងជោកជាំ មានស្វាមួយរងាញ័រចំប្រប់ ប្រតោងឡើងដើមឈើ ដើរចូលទៅជ្រកក្រោមសំបុកត្រលីងត្រលោងនោះ ។

បានឃើញដូច្នោះ បក្សីពោលថា:

– នែបងពានរ ក្បាល ដៃនឹងជើងរបស់បងឯង ដូចជាអវយវៈមនុស្សសុទ្ធវិស័យ ចុះហេតុអ្វីក៏បងគ្មានផ្ទះនៅ ?

ស្វាឆ្លើយថា :

– បងត្រលីងត្រលោងអើយ ក្បាល ដៃនឹងជើងរបស់ខ្ញុំ ដូចជាអវយវៈមនុស្សក៏ពិតមែន តែខ្ញុំមិនមានបញ្ញាដ៏ប្រសើរដូចជាមនុស្សទេ ។

ត្រលីងត្រលោងពោលបន្ទោស នឹងត្មះតិះដៀលដល់ស្វាថា:

– យកវាសកិច្ច នឹងសម្រេចដល់បងឯង ជាសត្វមានសភាពយ៉ាងនេះដូចម្ដេចបាន សេចក្ដីសុខក៏នឹងមិនមានដល់បង ដែលជាអ្នកខ្ជិលច្រអូស មានចិត្តរហ័ស អ្នកទ្រុស្ដមិត្រ នឹងមានកិរិយាមិនទៀងជានិច្ចនោះទេ ។ ម្នាលស្វា! បងឯង ត្រូវធ្វើខ្លួនឲ្យមានអានុភាពបន្តិចឡើង ត្រូវប្រព្រឹត្តកន្លងឲ្យផុតនូវសេចក្ដីខ្ជិលច្រអូស ត្រូវធ្វើខ្ទមសម្រាប់ការពារនឹងភ្លៀងខ្យល់ៗ

កាលនោះ ស្វានឹកតូចចិត្ត ហើយគិតថា! «ឃើអើ! អាគ្រលីងគ្រលោងនេះ វាថាអញជាអ្នកទ្រុស្ដមិត្រ បើដូច្នេះ មានតែអញ សំដែងកិរិយាទ្រុស្ដមិត្រឲ្យវាដឹងចុះ» ។

រួចស្វាក៏ចោចពេចសំបុកបក្សីរបើកខ្ចាត់ខ្ចាយអស់ ៗ ចំណែកគ្រលីងគ្រលោងភិតភ័យ ក៏ស្ទុះហើរយ៉ាងប្រញាប់ទៅកាន់ទីដទៃ ។

អដ្ឋកថាធម្មបទ

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ហិមពាន្ត ។ ២) ពានរ ។ ៣) អវយវៈ (អៈវៈយៈវៈ) ។ ៤) មនុស្សសុទ្ធវិស័យ ។ ៥) យកវាសកិច្ច (យៈកវាសៈកិច្ច) ។ ៦) ទ្រុស្ដមិត្រ ។

## ខ) សំនួរ

១) យ៉ាងដូចម្ដេចហៅថា: « បញ្ញាដ៏ប្រសើរ »? ២) ដែលសត្វក្រលីងក្រលោងនឹងបក្សីដទៃធ្វើសំបុករបស់វានោះ តើធ្វើដោយបញ្ញាឬធ្វើដោយអ្វី ? ៣) ដែលក្រលីងក្រលោង ពោលត្អូញត្អែរជៀលស្វា ក្នុងពេលដែលគ្មានអាសនជម្រក តើសមរម្យឬទេ ?

## គ) អត្ថរសទូទៅ

អត្ថបទនេះ នឹងអាចផ្ដល់ដល់អ្នកអានទាំងឡាយ នូវគតិដូចម្ដេចខ្លះ?

## ឃ) វេយ្យាករណ៍

ចូររកពាក្យជាវេវចនៈនឹងពាក្យ ៗ ចូររកពាក្យផ្ទុយនឹង «ខ្ជិល» — «ទ្រុស្ដមិត្រ» ។

## ង) និពន្ធសេចក្ដី

មិត្រអ្នកម្នាក់ ជាកូនអ្នកមានទ្រព្យគួរសមដែរ ប៉ុន្តែជាអ្នកស៊ីចាយឥតសណ្ដាប់ធ្នាប់ ។ លុះដល់ជិតមហាប្រវេសនកាល ប្រាក់ដែលឪពុកម្ដាយឲ្យមក មិត្រនោះចាយវាយអស់ ហើយមកសុំអង្វរខ្ចីប្រាក់អ្នកខ្លះ ដើម្បីយកទៅទិញប្រដាប់ប្រដាសិស្ស ដើម្បីសិក្សា ។

ចូរអ្នកពិពណ៌នារឿងនេះ ហើយបញ្ចេញយោបល់របស់អ្នក ចំពោះការចាយវាយឥតសណ្ដាប់ធ្នាប់នេះ ។

---

# សេនកបណ្ឌិត

ដំណាលថា មានតាព្រាហ្មណ៍យាចកម្នាក់ បានឈប់សម្រាកនាកណ្ដាលព្រៃ ក្បែរដើមប្រេសមួយដើម ដើម្បីបរិភោគក្រពង ។ លុះភុញ្ជនកិច្ចបានចប់ហើយ តាព្រាហ្មណ៍ក្ចបចងមាត់ស្បៀង ក៏ចុះទៅផឹកទឹក ក្នុងស្រះមួយ នៅជិតនោះ ។

គ្រានោះ មានពស់វែកតូចមួយ ដែលនៅក្នុងរន្ធដើមប្រេសនោះ ដោយធុំក្លិនក្រពង បានវារលូនចូលក្នុងស្បៀងដើម្បីស៊ីខំ ៗ តាព្រាហ្មណ៍ត្រឡប់ពីស្រះមកវិញ មិនបានមើលមើលខាងក្នុងស្បៀង ឲ្យជាក់លាក់ ចាប់ក្របួចចងមាត់ ហើយលើកស្ពាយដើរទៅ ។

មានទេវតាមួយអង្គ បានឃើញដូច្នោះ មានចិត្តអាណិត គ្រាន់តែពោលប្រាប់ថា: «ម្នាលតាព្រាហ្មណ៍ ថ្ងៃនេះបើតាទៅមិនដល់ផ្ទះទេ តានឹងត្រូវស្លាប់ ប្រសិនបើថ្ងៃនេះ តាទៅដល់ផ្ទះ ប្រពន្ធតានឹងត្រូវស្លាប់» ។

ដោយមិនដឹងជាមានរឿងហេតុអ្វី តាព្រាហ្មណ៍ក៏យំនឹងសេចក្ដីស្ដាប់ពេក យំផង ដើរផង ស្រាប់តែទៅដល់ទ្វារនគរពារាណសី ។

ខណៈពេលនោះ មហាជនកំពុងប្រជុំគ្នាក្នុងសាលាមួយ ដើម្បីស្ដាប់ធម៌របស់ព្រះពោធិសត្វ នាមសេនកបណ្ឌិត ។ តាព្រាហ្មណ៍យកពាក្យដែលទេវតាបានពោលក្នុងព្រៃ មកជម្រាបដល់សេនកបណ្ឌិត ហើយសួរបញ្ជាក់ថា:

– បពិត្របណ្ឌិត ខ្ញុំបាទបានឮសំដីមិនគាប់ប្រសើរនេះ ខ្ញុំបាទក៏យំណាស់ សូមលោកមេត្តាប្រាប់ហេតុ នៃសេចក្ដីស្លាប់របស់ខ្ញុំបាទ នឹងភរិយាខ្ញុំបាទ ឲ្យបានដឹងផង សោះព្រួយ ណាព្រះគុណ ។

ព្រះពោធិសត្វសួរថា:

– ម្នាលតាព្រាហ្មណ៍ ក្នុងស្បៀងរបស់តា មាននំចំណីអ្វីដែរឬទេ?

តាព្រាហ្មណ៍ឆ្លើយដំណាលថា:

– បាទលោកម្ចាស់ មាននំក្រូចក្នុងនោះ ។

– ថ្ងៃនេះ ពេលបាយព្រឹក តាពិសានំ នៅកន្លែងណា?

– នៅក្នុងព្រៃ ក្បែរគល់ឈើមួយ លោកម្ចាស់ ។

– ពេលដែលតាពិសាស្លា ហើយចុះទៅពិសាទឹក តើតាបានបិទមាត់ស្បោងផងទេ?

– បាទ មិនបានបិទទេ លោកម្ចាស់ ។

– បើដូច្នោះ ខ្ញុំសន្និដ្ឋានថា មានពស់វែកមួយវារចូលទៅក្នុងស្បោងដោយដឹងក្លិននំ ក្នុងពេលដែលតាអញ្ជើញចុះទៅពិសាទឹក ។

ព្រះពោធិសត្វប្រាប់ថា:

– ចូរតាដាក់ស្បោងនោះចុះមក យកទៅទុកនាកណ្ដាលពួកបរិស័ទ ស្រាយមាត់បេញចយទៅឈរឲ្យឆ្ងាយបន្តិច ហើយយកឈើគោះលម៉ើលៗ

តាព្រាហ្មណ៍ ក៏ធ្វើតាមបញ្ជាព្រះពោធិសត្វ ។ ខណៈនោះ ស្រាប់តែពស់វែកមួយ បើកពពាបញ្ចេញសំឡេង «ផែ! ផែ!» ហើយវារចេញមកៗ

តាព្រាហ្មណ៍ មានសេចក្ដីត្រេកអរពន់ពេក បានថ្លែងអំណរព្រះគុណដ៏ជ្រាលជ្រៅចំពោះសេនកបណ្ឌិត ហើយសូមលាព្រះពោធិសត្វត្រឡប់ទៅទីលំនៅអាត្មា នៅជាសុខតរៀងទៅ ។

មង្គលត្ថទីបនី

## ក) ពន្យល់ពាក្យនិងសំនួនវោហារ

១) សេនកបណ្ឌិត (សេនកៈបណ្ឌិត ។ ២) ព្រាហ្មណ៍ ។ ៣) យាចក ។ ៤) រុក្ខទេវតា ។ ៥) ទ្វារនគរ ។ ៦) ពោធិសត្វ ។

## ខ) សំនួរ

១) បើពស់នៅរស់ ហេតុម្ដេច ក៏តាព្រាហ្មណ៍លើកស្បោងស្ពាយដើរទៅ ហើយមិនដឹងជាមានពស់? ២) ហេតុម្ដេច ក៏ទេវតាដឹងជាមានពស់ នៅក្នុងស្បោងតាព្រាហ្មណ៍?

## គ) អត្ថរសទូទៅ

និទាននេះ អាចផ្ដល់នូវគតិដូចម្ដេចខ្លះ ដល់អ្នកអានទាំងឡាយ?

## ឃ) វេយ្យាករណ៍

ចូររកពាក្យជាសមានសព្ទនឹង «គ្រា» – «វារ» ។

## ង) និពន្ធសេចក្ដី

ថ្ងៃមួយ អ្នកទៅព្រៃ ដើម្បីរកអុសជាមួយនឹងមិត្តរបស់អ្នក ហើយមិត្តនេះ បានកាប់អុសក្អាត់កាំបិតមកត្រូវដៃ មានឈាមហូរចេញយ៉ាងច្រើន ។

ចូរអ្នកពិពណ៌នារឿងនេះ ហើយនឹងវិធានការដែលអ្នកត្រូវធ្វើ ដើម្បីជួយសង្គ្រោះមិត្តអ្នកឲ្យរួចជីវិត នាំមកដល់មន្ទីរពេទ្យ ។

---

## គោពីរ

(បទកាកគតិ)

កាលនោះគោពីរ　ចូលហ៊ុនរកត្រី　ក្នុងស្ទឹងគង្គា
ទើបផ្ដើមចរចា　ប្ដេជ្ញានឹងគ្នា　បើបានមច្ឆា
　ចែកភាគឲ្យស្មើ ។
សមគ្គីសមគ្គា　សត្វទាំងទ្វេហារ　ប្រឹក្សាថាបើ
ឈ្នះយើងធ្វើម្ដេច　ទើបលេចប្រសើរ　កិច្ចការសរពើ
　ក្នុងការនេសាទ ។
ខាងក្រោយត្រិះរិះ　គេទាំងពីរនេះ　សម្រេចយ៉ាងស្អាត
ត្រូវយើងបែងចែក　ជាផ្នែកដាច់ខាត　អ្នកមួយសង្វាត
　ខាងទឹកកក់ណា៎ ។
អ្នកមួយដទៃ　ខំប្រឹងកែខៃ　ត្រាច់ក្នុងដលសា៎

ប៉ែកខាងទឹកជ្រៅ ទីនៅមច្ឆា ហក់ទៅខាងណា
មិនប្រែពីដើម ។

ជាក្លាមស្មុះរឹង ឥតរង់ទទឹង ក្នុងគង្គាល័យ
គេពីមុជផ្ទឹប ពន្ទឹបខ្លួនវៃ ដាក់គ្នាសំរៃ
ទឹកខ្ទាត់ផាត់កាយ ។

មិនយូរប៉ុន្មាន គេទាំងពីរប្រាណ ងើបឡើងសប្បាយ
បានជួនជុំមួយ កាន់សួយនៅកាយ ហែលចូលមកអាយ
ឡើងប្រាំងសម្រាក ។

ការណ៍ត្រង់នេះឯង គេយើងបំបែង ក្នុងចិត្តពិបាក
គិតគូរដូចម្ដេច សម្រេចស្មើភាគ តាមកិច្ចសត្យពាក្យ
សន្យាទុកមក ។

ចតុបាទា ដណ្ដើមត្រូវការ ដោយចិត្តពាលក
ចង់តែខាងក្បាល ត្រអាលគិតក្អក ពុំបេះរិះរក
ឧបាយឲ្យស្ងប់ ។

ម្ល៉ោះហើយកើតជា ជជែកឈ្លោះគ្នា មិនអស់មិនចប់

ចង់តែខានក្បាល　　វៀងពល់ឥតឈប់　　អួតអាងប្រសប់
បំណាច់អាត្មា ។

ក្បិណនោះមែនមាន　　ចចកចាស់ប្រាណ　　មួយចរយាត្រា
ឫកដូចមន្ត្រី　　សំដីវោហារ　　ក្បែរទីរាទការណ៍
នៃភេទាំងពីរ ។

ពាលោពាលា　　ចតុប្បាទា　　ទុនក្រាបសិរសី
អង្វរសូមយក　　ចចកអប្រិយ៍　　ឲ្យជួយកាត់ក្តី
រឿងបែកមច្ឆា ។

ចចកបានដៃ　　ចិត្តនឹករំពៃ　　រំពឹងលាភា
តែមាត់ប្រកែក　　ធ្វើស្រែកមាយា　　ដុំកើងអាត្មា
ជាលោកចៅក្រម ។

ខ្ញុំទើបណាតលា　　ចុះពីសាលា　　មន្ទីរជំនុំ
កាត់ក្តីជាច្រើន　　ក្រវើនពេកពុំ —　　ហ៊ានឈប់សំងំ
ខំដើរកំសាន្ត ។

ប្ទះគ្នានវេលា　　ឈប់ជួយផ្សះផ្សា　　រវល់ហាត់ប្រាណ

ដើរឲ្យដើងដៃ សរសៃសប៉ុន្ទាន ស្រួលហើយទុកគ្រាន់

តែធ្វើពផការ ។

ទទួបអង្ករ កេតីរលើគគរ សំពះវន្ទា

បបកជាបាន តែប្រាណពល់គ្នា គោរពរាថា

នៃលោកចៅក្រម ។

រួបរយកត្រី មកបែងកាត់ក្រី ធ្វើជាបដុំ

ភាគក្បាលត្រូវចែក ទៅផ្នែកអ្នកខំ មុជស្ងិតសំងំ

ក្នុងទឹកជ្រៅ ។

ឯភាគកន្ទុយ បានដល់អ្នកលុយ — លុកក្បែរប្រាំងនៅ

ឯភាគសំខាន់ រង្វាន់ខាន់ខៅ របស់លោកចៅ-

ក្រមអ្នកវិនិច្ឆ័យ ។

ថាហើយបបក ខាំពាំយកមក ដើរជៀសនិរភ័យ

ទុកឲ្យតៃរី វក់វីស្មើរក្សៀយ នកស្ដាយអាល័យ ។

ធ្វើក្អែកម៉កម៉ក ។

ដើង–ជ្រឹរ

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ស៊ឹងគគ្គា ។ ២) មច្ឆា ។ ៣) សមគ្គីសមគ្គា ។ ៤) វោហារ ។ ៥) ផលសា ។ ៦) គគ្គាល័យ ។ ៧) ថ្នឹន ។ ៨) ចតុប្បាទា ។ ៩) ពាលក (ពាលក់) ។ ១០) មន្ត្រី ។ ១១) ភ្ញៀវការណ៍ ។ ១២) មាយា ។ ១៣) លើកករ ។ ១៤) និរភ័យ ។

## ខ) ផែនការ

ចូររកសង្កាត់កង់អត្ថបទនេះ តើមានប៉ុន្មាន? ហើយចូរឲ្យនាមដល់សង្កាត់នីមួយ ៗ ។

## គ) សំនួរ

១) គេអាចចែកត្រីឲ្យមានភាគស្មើគ្នាបានឬទេ? ២) ហេតុម្តេចបានជាអ្នកនិពន្ធជ្រើសយក «ចចកចាស់» មកជាតួទី ៣? ៣) តើគេចង់ប្រដូចទៅនឹងអ្នកណា? ៤) ហេតុម្តេចបានជាមុនដំបូង ចចកប្រកែកមិនព្រមធ្វើជាអ្នកវិនិច្ឆ័យ? ៥) សេចក្តីត្រង់ណា ដែលអាចធ្វើ មិនឲ្យគេហ៊ានតវ៉ាចំពោះការវិនិច្ឆ័យរបស់ចចក?

## ឃ) អត្ថសេទូទៅ

អត្ថបទនេះ នឹងបានជាគតិដល់អ្នកអានដូចម្តេចខ្លះ?

## ង) វេយ្យាករណ៍

១) ចូររកពាក្យជាវេវចនៈ នឹង «ផលសា» ។ ២) ចូររកពាក្យជាសទិសសព្ទ នឹង «ករ» (លើកករ)។ ៣) ពាក្យក្ស័យ (នឿយហត់ស្ទើរក្ស័យ) មកពីភាសាអ្វី?

## ច) និពន្ធសេចក្តី

នៅភូមិអ្នក មានមនុស្សពីរនាក់ ទាស់គ្នាអំពីរឿងព្រំដី ។ មានចាស់ព្រឹទ្ធាចារ្យក្នុងស្រុក បាននិយាយផ្សះផ្សាដែរ តែគូប្រឆាំង ពុំព្រមស្តាប់ ហើយប្តឹងមកដល់តុលាការ សុំឲ្យជំនុំជំរះ ។

ចូរអ្នកអត្ថាធិប្បាយរឿងខាងលើនេះ ព្រមទាំងបញ្ជាក់ នូវលទ្ធផលជាអវសាន នៃការកើតក្តីផង ។

---

# នាងឧម្មាទន្តី

នារីនេះ លុះដល់សោឡសវស្សាហើយ ក៏មានរូបសម្បត្តិល្អស្អាត កន្លងអស់ស្រីផងទាំងពួង ប្រៀបបាននឹងស្រីទេពអប្សរ ។ មនុស្សជាបុថុជ្ជន កាលបើបានយល់រូបនាងហើយ មិនអាចទប់សភាពខ្លួនបានឡើយ ទៅជាងឹងងោង ដូចគេស្រវឹងស្រា ហើយមិនអាចតាំងស្មារតីឲ្យនឹងនៅបាន ។

មហាសេដ្ឋីឈ្មោះ «តិរិដិវច្ឆ» អញ្ជើញទៅក្រាបបង្គំគាល់ព្រះស្រីពជា ហើយក្រាបបង្គំទូលថា :

– បពិត្រព្រះសម្មតិទេព ស្ត្រីរតន៍បានកើតក្នុងគេហស្ថាននៃទូលព្រះបង្គំជាខ្ញុំ នាងនេះមានសភាពដ៏សក្តិសមដល់ព្រះអង្គ សូមទ្រង់ព្រះមេត្តាបញ្ជូនព្រាហ្មណ៍អ្នកទាយលក្ខណៈ ឲ្យទៅពិនិត្យនាងនារីនោះ ។

ព្រះបរមពជា ទ្រង់បញ្ជូនព្រាហ្មណ៍បួននាក់ ឲ្យទៅសង្កេតលក្ខណៈមើល ៗ កាលបើព្រាហ្មណ៍ទាំងបួននាក់បានទៅដល់ហើយ មហាសេដ្ឋីបានជប់លៀង ដោយបណីតាហារដ៏សមគួរ ៗ ខណៈនោះ កញ្ញាឧម្មាទន្តី

ចេញមកបំរើភ្ញៀវ ។ អាគន្តុកព្រាហ្មណ៍ ដែលបានយល់នាងហើយ មិនអាចទប់ស្មារតីបាន ក៏ទៅជាមនុស្សស្រវឹងដោយកិលេស ហើយមិនដឹងជាអាត្មា មានការបរិភោគប្រែប្រួលឡើយ ។ ព្រាហ្មណ៍ខ្លះ ចាប់ដុំបាយដោយស្មានជាដាក់ក្នុងមាត់ ត្រឡប់ជាយកទៅដាក់លើក្បាល ព្រាហ្មណ៍ខ្លះទៅគោះជញ្ជាំង ខ្លះទៀតចាប់ដុំបាយយកមកបញ្ចូលរន្ធត្រចៀក ។ ព្រាហ្មណ៍ទាំងឡាយវង្វេងស្មារតី ត្រឡប់ដូចជាមនុស្សឆ្កួត ។

បានឃើញព្រាហ្មណ៍ធ្វើដូច្នោះ ឧម្មាទន្តី បង្គាប់មនុស្សក្នុងផ្ទះ ឲ្យនាំចេញទៅក្រៅ ហើយស្តីបន្ទោសដូច្នេះថា:

– ព្រាហ្មណ៍ទាំងនេះ ក្រែងព្រះមហាក្សត្របញ្ជូនមក ឲ្យពិនិត្យលក្ខណៈរបស់ខ្ញុំឬ? ហេតុម្តេច ក៏មកធ្វើអាពុកយ៉ាងនេះ ។

ព្រាហ្មណ៍ទាំងបួននាក់ មានសេចក្តីខ្មាសអៀនក្រៃពេក ថែមទាំងអន់ចិត្តចំពោះនាងផង ទើបទៅក្រាបបង្គំទូលក្លែង ចំពោះព្រះមហាក្សត្រថា:

– បពិត្រព្រះអង្គដ៏ចំរើន! កញ្ញាឧម្មាទន្តី ជាស្ត្រីកាឡកិណ្ណីទេ មិនមានលក្ខណៈដ៏សមរម្យដល់ព្រះអង្គឡើយ ។

ព្រះមហាក្សត្រិយ៍ ទ្រង់មានព្រះបន្ទូលឆ្លើយតបថា:

– មេនារីនោះ ជាស្រ្តីគាឡកណ្ណី កុំនាំមកធ្វើអ្វី ។

ចំណែកញាណឧម្មាទន្តី កាលបើដឹងពាក្យទូលបង្គាប់នៃព្រាហ្មណ៍ដូច្នោះ ក៏មានសេចក្តីគុំកួននឹងព្រះមហាក្សត្រ ហើយនឹកថា: «មិនអីទេ ជាដូចម្តេចក៏ដោយចុះ ចាំមើលពេលក្រោយ គង់តែនឹងដឹង» ។

លំដាប់តមក សេដ្ឋីជាបិតា បានឲ្យនាងឧម្មាទន្តី ទៅជាភរិយានៃសេនាបតីម្នាក់ឈ្មោះ អភិបារកោ ជាសំឡាញ់នឹងព្រះមហាក្សត្រ ។ នារីនេះ ជាទីស្នេហានឹងជាទីគាប់ចិត្តយ៉ាងពន់ពេក ដល់លោកសេនាបតី ។

មង្គលត្ថទីបនី (នៅមានត)

---

# នាងឧម្មាទន្តី

(តបប់)

សម័យមួយ លោកសេនាបតីជាស្វាមី មុននឹងចេញទៅធ្វើការ បានប្រាប់ភរិយាថា:

– ថ្ងៃនេះជាថ្ងៃពេញបូណ៌មីខែកត្តិក ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង នឹងស្តេចយាង ធ្វើប្រទក្សិណព្រះនគរ ព្រះអង្គនឹងស្តេចយាងតាម

មុខផ្ទះយើងនេះ មុនគេបង្អស់ ប្អូនកុំបង្ហាញខ្លួនឲ្យព្រះអង្គយល់ ដ្បិតថា បើព្រះអង្គបានទតយល់រូបប្អូនហើយ មុខជាព្រះអង្គ មិនអាចទប់ព្រះស្មារតីបានឡើយ ។

នាកាលព្រះអាទិត្យអស្តង្គតហើយ ៗ ព្រះចន្ទរះឡើង បញ្ចាំងរស្មីភ្លឺចិញ្ចែង ឮដ៏នកាល័យ ព្រះមហាក្សត្រ ទ្រង់ស្តេចយាងប្រទក្សិណព្រះរាជធានី មួយអន្លើដោយព្រះរាជបរិវារជាច្រើន ។ ព្រះអង្គទ្រង់ស្តេចទៅដល់ទ្វារផ្ទះលោកសេនាបតីជាបឋមមែន ៗ ព្រះអង្គបានទតយល់នាងឧម្មាទន្តីអង្គុយ នៅក្បែរបង្អួច ។ កាលបើទ្រង់ទតយល់ដូច្នោះហើយ ព្រះរាជាមិនអាចញ៉ាំងព្រះស្មារតីឲ្យតាំងនៅដោយត្រឹមត្រូវបាន ព្រះអង្គឈប់ត្រូវការកន្លងកិច្ចប្រទក្សិណព្រះនគរ ស្តេចយាងត្រឡប់អំពីទីនោះ ចូលព្រះបរមរាជវាំង ស្តេចឡើងផ្ទុំក្នុងប្រាសាទ ប្រារព្ធនូវនាងឧម្មាទន្តី ហើយមានព្រះបន្ទូលរវើរវាយដោយប្រការផ្សេងៗ ។

លោកសេនាបតី បានដឹងរឿងនោះភ្លាម ទើបគិតថា: «ព្រះករុណាពិតជាមានព្រះរាជហឫទ័យ ប្រតិព័ទ្ធក្នុងរូបនាងឧម្មាទន្តី បើមិនបាននាង

មកជាព្រះជាយាទេ នោះព្រះអង្គទៀនតែនឹងសុគត ដូច្នេះត្រូវតែអញជួយស្រង់ព្រះជន្មរបស់ព្រះអង្គទើបគួរ” ។

គិតតែម្ល៉ោះហើយ លោកបង្គាប់អ្នកបំរើម្នាក់ថា:

– ចូរឯងទៅ នៅក្នុងទីឯណោះ មានដើមប្រេសមួយ មានរូងខាងក្នុង ឯងលបចូលទៅអង្គុយក្នុងរូងនោះ កុំឲ្យនរណាដឹងឲ្យសោះ អញនឹងទៅក្នុងទីនោះធ្វើពលិកម្ម រួចពោលយ៉ាងនេះ លុះអញបាននិយាយរួច ត្រូវឯងថាដូច្នេះតបមកវិញ ។

អ្នកបំរើទទួលព្រម ហើយក៏ទៅអង្គុយនៅក្នុងរូងដើមប្រេសនោះ ។

ព្រឹកស្អែក លោកសេនាបតី អញ្ជើញទៅឯដើមប្រេសធ្វើពលិកម្ម ហើយសួរថា:

– បពិត្រលោកទេព្រក្សដ៏ចម្រើនអើយ កាលមហាស្រពកើតមានហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនៃយើងខ្ញុំទាំងឡាយ មិនទ្រង់ក្រសាលសោះ ព្រះអង្គទ្រង់ព្រះនិវត្តចូលក្នុងប្រាសាទវិញ ផ្ទំរើរវាយ តើដែលព្រះអង្គមានព្រះបន្ទូលរើរវាយនេះ មកពីហេតុអ្វី ?

បុរសអ្នកបំរើ ធ្វើសំឡេងឲ្យប្លែក ហើយឆ្លើយតបថា:

– ម្នាលលោកសេនាបតី ព្រះករុណារបស់លោក មានព្រះរាជហឫទ័យប្រតិព័ទ្ធកន្ញរូបនាងឧម្មាទន្តីជាភរិយារបស់លោក បើព្រះអង្គមិនបាននាងមកជាព្រះមហេសីទេ នោះព្រះអង្គនឹងសុគតជាព្រាកដ ហេតុនេះ ត្រូវលោកថ្វាយនាងទៅព្រះអង្គទើបគួរ ។

លោកសេនាបតី ឆ្លើយទទួលព្រម តាមសំដីនៃទេព្រតាថា: «សាធុ សាធុ» ។

រួច លោកអញ្ជើញទៅកាន់ព្រះមហាក្សត្រ ក្រាបបង្គំទូលថ្វាយនូវដំណើរខាងលើ ហើយក្រាបបង្គំទូលថ្វាយសេចក្ដីដូច្នេះថា:

– បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គ ។

ព្រះបរមរាជាទ្រង់ត្រាស់សួរថា:

– ម្នាលអភិបារកោជាសំឡាញ់ អីទេតា ទេព្រតាទាំងឡាយបានដឹងថា ដែលយើងនិយាយរវើរវាយនេះ ព្រោះតែជាប់ចិត្តកន្ញរូបនាងឧម្មាទន្តី!

– សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។

ព្រះពុទ្ធជាទ្រង់ព្រះចិន្តាថាៈ "ឥឡូវមនុស្សព្រមទាំងទេវតា ដឹងនូវការៈ ដ៏មិនសមរម្យនៃអាត្មាអស់ហើយតើ អាត្មាអញជាព្រះមហាក្សត្រគ្រប់គ្រងផែនដី នឹងអាណាប្រជានុរាស្ត្រ ដូច្នេះ មិនសមឲ្យសេចក្ដីស្នេហាញាំញីនោះ ។

សេចក្ដីអៀនខ្មាស ក៏បានកើតឡើងចំពោះព្រះអង្គ រួចព្រះអង្គទ្រង់តាំងព្រះរាជហឫទ័យឲ្យស្ថិតនៅក្នុងធម៌ បន្ទោរបង់នូវសេចក្ដីប្រតិព័ទ្ធចេញ ហើយព្រះអង្គ ឈប់ត្រូវការនឹងនាងឧម្មាទន្តីជាដាច់ខាត ។

មង្គលត្ថទីបនី

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) សោឡសវស្សា (សោឡោះវស្សា) ។ ២) សម្មតិទេព (សាំមៈតិទេព) ៣) ស្រីរតន៍ ។ ៤) បណ្ណាការ ។ ៥) អាគន្តុកព្រាហ្មណ៍ (អាគន្តុកៈព្រាហ្មណ៍) ។ ៦) កិលេស ។ ៧) អាពព្ធក ៨) កាឡកិណ្ណី ។ ៩) ប្រទក្សិណព្រះនគរ ។ ១០) ប្រារព្ធនូវនាងឧម្មាទន្តី ។ ១១) ពលិកម្ម ។ ១២) ទេព្រក្ស (ទេព្រាក់) ។ ១៣) មហោស្រព ។ ១៤) មនុស្សជាបុថុជ្ជន ។

## ខ) សំនួរ

១) ដោយអំណាចអ្វី បានជាព្រាហ្មណ៍ទាំងបួន ទៅជាមនុស្សវេវើរវាយទឹងព្រុសបាតស្មារតី ?

២) ហេតុអ្វីបានជាព្រះមហាក្សត្រជាន់ដើម តែងទ្រង់ប្រទក្សិណព្រះរាជធានី ក្នុងមួយឆ្នាំម្តង ?

៣) លោកសេនាបតី យល់ហេតុយ៉ាងណា បានជាធ្វើឧបកិច្ចដូច្នេះ ដើម្បីស្រង់ព្រះជន្មព្រះមហាក្សត្រ ?

៤) លោកសេនាបតី មានបំណងទឹងថ្វាយនាងឧម្មាទន្តី បំពោះព្រះរាជាមែនឬ ៗ គ្រាន់តែពោលដោយមាត់ទទេ ?

## គ) អត្ថរសទូទៅ

កាលបើយើងបានអានអត្ថបទនេះ តើយើងអាចទាញនូវគតិដូចម្តេចដើម្បីជាគ្រឿងប្រតិបត្តិតទៅ ?

## ឃ) វេយ្យាករណ៍

១) ចូរស្រង់ពាក្យណាដែលប្រើក្លាយមកពីភាសាបាលី នៅក្នុងអត្ថបទនេះ ព្រមទាំងពាក្យក្លាយមកពីភាសាសំស្ក្រឹតផង ។

២) ចូររកពាក្យជាវេវចនៈ នឹង «ព្រះរាជា»–«សេនាបតី» ។

## បុរស នឹង សេក

មានបុរសម្នាក់ មានភរិយាប្រកបដោយរូបសម្បត្តិល្អប្រពៃ ។ បុរសនោះ ស្រឡាញ់ភរិយាអាត្មាហួសប្រមាណ មិនដែលទៅណាឲ្យឃ្លាតឆ្ងាយមួយយប់ឡើយ ។

ថ្ងៃមួយ ដោយមានធុរៈ ដើម្បីទៅស្រុកឆ្ងាយនឹងខានពុំបាន បុរសជាប្ដី ក៏ទៅឯកន្លែងលក់បក្សី ហើយទិញសេកមួយយកមក ។ ឯសេកនោះ មិនគ្រាន់តែចេះនិយាយភាសាមនុស្សប៉ុណ្ណោះទេ ថែមទាំងមានប្រាជ្ញាវាងវៃ នឹងចេះចាំរឿងរ៉ាវផ្សេងៗ ដែលគេបានដឹងបានឮនោះផង ។ បុរសយកសេកដាក់ទ្រុង ហើយនិយាយប្រាប់ភរិយាឲ្យយកទៅចិញ្ចឹមទុកក្នុងបន្ទប់ ថែរក្សាឲ្យស្រួលល្អ ក្នុងពេលដែលខ្លួនមិននៅ ។ លុះផ្ដែផ្ដាំស្រេចហើយ បុរសជាប្ដីក៏ធ្វើដំណើរចេញទៅ ។

លុះត្រឡប់មកផ្ទះវិញ បុរសជាប្ដីចូលទៅពិចារណាសួរសេក អំពីហេតុភេទ ដែលបានកើតមានឡើង ក្នុងគ្រាដែលខ្លួនបានឃ្លាតទៅឆ្ងាយ ។ សេកបានឆ្លើយប្រាប់អស់អាថិកិច្ចការ ដែលនាំឲ្យស្វាមីស្ដីបន្ទោសជាទម្ងន់

ផល់កិរិយា ។ នាងនេះ ដោយគិតស្មានថាមានទាសីណាម្នាក់ក្នុងផ្ទះ លួច

ប្រាប់រឿងរ៉ាវសំងាត់នេះ ទើបហ៊ានស្បថស្បែចំពោះប្ដី ថាខ្លួនមានចិត្ត

ស្មោះត្រង់ ឥតមានវៀចវេរប្រែប្រួលឡើយ ។ ពេលក្រោយមក នាង

ប្រពន្ធទើបបានដឹងថា រឿងរ៉ាវទាំងប៉ុន្មាននេះ បែកមកតែពីសេកបង្រៃទេ

តើ រ៉ាបាននិយាយប្រាប់ប្ដីខ្លួន ។

កាលបើបានដឹងដូច្នោះហើយ នាងប្រពន្ធគិតរកកលឧបាយ ដើម្បី

បំបាត់សេចក្ដីសង្ស័យរបស់ប្ដីផង និងដើម្បីញុាំងសេកនោះឲ្យវិនាសផង ។

ខាងក្រោយការត្រិះរិះ នាងកិរិយាឃើញមធ្យោបាយដូចតទៅ:

ក្នុងវេលាដែលប្ដីមានដំណើរទៅឆ្ងាយ កំណត់មួយទីវាពត្រីយប់នោះ

នាងកិរិយាប្រើទាសីម្នាក់ ឲ្យយករហាត់ទៅវិរនៅក្រោមទ្រុងសេក ទាសី

ម្នាក់ទៀត យកទឹកទៅបាចសាចពីលើដំបូលទ្រុង ធ្វើដូចជាភ្លៀង ទាសី

ផ្សេងម្នាក់ទៀត យកកញ្ចក់ទៅបញ្ចាំងដោយពន្លឺភ្លើងទៀន ពីខាងត្បូងម្ដង

ពីខាងស្ដាំម្ដង តាំងពីព្រលប់ផល់យប់ជ្រៅទើបឈប់ ។

ព្រឹកស្អែក ប្តីត្រឡប់មកផ្ទះវិញ ហើយទៅសួរពិចារណាទីងសេក ទៀត នូវហេតុដែលបានកើតមានកងផ្ទះ ។ ឯសេកឆ្លើយប្រាប់ថា: "ឱម្ចាស់ខ្ញុំអើយ វេលាយប់មិញនេះ ក្មេងផ្តរម្ជើទុកទាល់ក្តី ខ្ញុំបាទមាន សេចក្តីលំបាកឥតឧបមា" ។

ប៉ុន្តែ កងយប់មិញនេះ បុរសជាប្តី បានដឹងប្រាកដថា ឥតមានក្មេង សោះ ។ និមិត្តតែបានឮសំដីសេកដូច្នោះ បុរសកំណាច យល់ថាសេក ពោលពាក្យមុសាវាទ គឺថាពាក្យដែលសេកបានប្រាប់ដល់ខ្លួន អំពីកិរិយា នឹងមារយាទមិនសមរម្យនៃភរិយា កាលជាន់មុន សុទ្ធសឹងជាពាក្យមួល បង្កាច់ ជាពាក្យកុហក មិនពិតទាំងអស់ ។ រួចបុរសជាប្តី លូកចាប់យកសេក ពីកងទ្រុង ហើយបោកផ្ទប់ទៅទីងដី បក្សីក៏អន្តរាយជីវិតកងគ្រានោះ ។

បំណោរជាខាងក្រោយមក ទើបបុរសជាស្វាមី បានដឹងហេតុពិត អំពីអ្នកជិតខាង ថាសេកនោះ មិនបានពោលពាក្យកុហក បង្កាច់កិរិយា មារយាទភរិយាខ្លួនទេ ។ បុរសម្ចាស់សេក កាលបើបានដឹងដូច្នេះហើយ ទើបកើតសេចក្តីសោកស្តាយមហិមា នូវបក្សីជាទីពេញចិត្ត ដោយខ្លួន បានពិឃាដចោល ឥតពិចារណា ។

មួយពាន់មួយយប់

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

*១) អាថិកិច្ចការ ៗ ២) ទិវាពត្រ័ ៗ ៣) ឥតឧបមា ៗ ៤) និមិត្តតែ ៗ ៥) មហិមា (មៈហិមា) ៗ*

## ខ) សំនួរ

*១) ហេតុអ្វីបានជាបុរសទិញសេក យកមកឲ្យប្រពន្ធទុកបំពាំម ? ២) ដោយប្រការយ៉ាងណា បានជាបុរស បង្គាប់ឲ្យប្រពន្ធយកសេកទៅបំពាំមនៅក្នុងបន្ទប់? ៣) ប្ដីស្ដីបន្ទោសប្រពន្ធអំពីរឿងអ្វី? ៤) ដែលនាងប្រពន្ធបង្គាប់ឲ្យទាសីយកគញ្ចក់មកបញ្ចាំងទឹងក្បែងទៀន ពីខាងត្បូងមួង-ខាងស្ដាំមួង ដើម្បីប្រយោជន៍អ្វី?*

## គ) អត្ថរសទូទៅ

*អត្ថបទនេះ នឹងអាចផ្ដល់ផលអ្នកអានទាំងឡាយ នូវគតិដូចម្ដេច?*

## ឃ) វេយ្យាករណ៍

*១) ចូររកពាក្យជាសន្ធាននឹង «បន្ទោស» ៗ ២) ចូររកពាក្យផ្ទុយនឹង «ទាសី» ៗ ៣) ចូររកពាក្យជាវេវចនៈនឹង «ដើ» ៗ ៤) គ្រង់ពាក្យ*

„តាំងពីព្រលឹមដល់យប់ជ្រៅ" ហេតុម្ដេចបានជាគេមិនសរសេរ „ប្រលិម" ?

៥) ចូររកពាក្យផ្សេងដទៃ ដែលមានលំនាំប្រហែលគ្នានេះខ្លះមកមើល ?

---

# ព្រានដំរី

ក្នុងកាលកន្លងទៅហើយ កាលនោះ នៅក្នុងដែនកាសី នាមជ្ឈិមប្រទេស មានព្រានដំរីម្នាក់តែងពិឃាដដំរីយកភ្លុក យកសាច់នឹងស្បែកលក់យកកម្រៃ ដើម្បីចិញ្ចឹមជីវិតជារៀងរាល់ថ្ងៃ ។

សម័យនោះ មានហ្វូងដំរីជាច្រើននៅក្នុងព្រៃ ដែលជាកន្លែងជាទីគង់អាស្រ័យនៃព្រះបច្ចេកពុទ្ធទាំងឡាយ ។ ទោះទៅក្ដី ឬត្រឡប់មកវិញក្ដី ដំរីទាំងនោះតែងលុតជង្គង់ថ្វាយបង្គំព្រះបច្ចេកពុទ្ធ រួចទើបដៀសចេញទៅ ។

ថ្ងៃមួយ កាលបើបានឃើញកិរិយាដ៏ប្លែកនោះ ព្រានដំរី ទើបគិតថា "សព្វថ្ងៃ អញសម្លាប់ដំរីបានដោយកម្រណាស់ . ប្រសិនបើអញបានសំពត់កាសាវៈមកស្លៀកដណ្ដប់ នោះអញនឹងអាចសម្លាប់ដំរីបានដោយងាយ" ។

គិតដូច្នោះហើយ ព្រានដំរីទៅលួចយកចំពារព្រះបច្ចេកពុទ្ធមួយអង្គ ដែលដោះទុកនៅមាត់ជាតស្រះ ហើយនិមន្តចុះទៅស្រង់ទឹក ។ រួចព្រាន អបលក្ខណ៍យកសំពត់នោះមកដណ្ដប់ទទូរក្បាលជិត កាន់លំពែងលាក់ ខាងក្នុង ហើយទៅពួនប្រចផ្លូវដែលដំរីទាំងឡាយធ្លាប់ដើរទៅមក ។ ព្រាន នោះតែងប្រហារយ៉ាងដូច្នេះ នូវដំរីណាដែលដើរទៅក្រោយគេ ហើយ ពន្លះយកតែអវយវៈដែលគួរយក មានភ្លុកជាដើម ចំណែកវត្ថុដ៏សេស កប់ ចោលក្នុងដីទាំងអស់ ។

ចំណេរមកខាងក្រោយ ស្ដេចដំរី កាលបើបានដឹងថាបរិស័ទអាត្មា វិនាសអស់ច្រើន ក៏រង្កៀសក្នុងចិត្តថា: «សេចក្ដីអន្តរាយនេះ ប្រាកដជា កើតមានមកពីសំណាក់បុរសម្នាក់ ដែលស្លៀកដណ្ដប់សំពត់កាសាវៈ ហើយដែលអង្គុយពួនអាត្មា ក្នុងទីមួយនោះដោយពិត» ។

លុះត្រិះរិះយ៉ាងនេះហើយ ស្ដេចដំរីទើបបញ្ជូនបរិវារឲ្យដើរទៅមុន ទាំងអស់ ចំណែកខ្លួនឯងត្រាច់តាមក្រោយ ដើម្បីរំពៃឃ្លាំមើល ។ ឯ ព្រាននោះ កាលបើបានឃើញដំរីមួយដើរដាច់តែឯង ក៏ក្រវាត់ចំពារចេញ ពួយលំពែងសំដៅស្ដេចដំរីៗគេចផុត ស្ទុះទៅចាប់ព្រានរួបដាប់នឹងឈើមួយ

ដើម ហើយគិតនឹងបោកសំឡាប់ ។ លុះក្រឡេកទៅឃើញសំពត់កាសាវៈ ទើបស្ដេចដំរីគិតថា: "បើអញប្រទូស្ដនឹងព្រាននេះ មុខជានឹងមានសេចក្ដីអៀនខ្មាសដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ" ។

កាលបើអត់សង្កត់ចិត្តបានហើយ ទើបស្ដេចដំរីសួរព្រានថា:

– ដំរីជាញាតិរបស់អញ ឯងធ្វើឲ្យវិនាសឬ?

ព្រានឆ្លើយទទួលសារភាពថា:

– មែនដូច្នោះហើយ លោកម្ចាស់ ។

ស្ដេចដំរីពោលត្មះតិះដៀលថា:

– អ្នកឯងដែលធ្វើបាបកម្មមានទម្ងន់យ៉ាងនេះ មិនគួរនឹងស្លៀកដណ្ដប់សំពត់កាសាវៈសោះ ។

អដ្ឋកថាធម្មបទ

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) កាសី ។ ២) មជ្ឈិមប្រទេស ។ ៣) ព្រះបច្ចេកពុទ្ធ ។ ៤) ព្រានអបលក្ខណ៍ ។ ៥) សំពត់កាសាវៈ ។ ៦) ចីពរ ។ ៧) ជាតស្រះ ។ ៨) ព្រះខីណាស្រព ។ ៩) ប្រទូស្ដ ។

### ខ) ផែនការ

អត្ថបទនេះ ចែកជាសង្កាត់មានប៉ុន្មាន ? ចូរឲ្យនាមដល់សង្កាត់ទីមួយៗ ។

### គ) និពន្ធសេចក្ដី

ចូរពិពណ៌នា នូវពិធីណាមួយ ដែលអ្នកបានសង្កេតមើល ហើយនិងប្រយោជន៍នៃពិធី ។

---

## ការដោះបញ្ហានៃកាឡាហ្វ

ទូនរ៉ានដុក ជាព្រះរាជធីតានៃព្រះចៅអាទូនខាន់ នៃប្រទេសចិន ។ ព្រះនាងមានប្រាជ្ញាឆ្លាតវាងវៃ លើសអស់អ្នកប្រាជ្ញទាំងពួងក្នុងប្រទេស ។ មានបុត្រព្រះមហាក្សត្រច្រើនអង្គ ដែលទ្រង់សព្វព្រះហឫទ័យ ចង់បានព្រះនាងជាព្រះមហេសី ទ្រង់សុគតទៅ ព្រោះតែដោះប្រស្នារបស់ព្រះនាងពុំរួច ។ ឥឡូវបុត្រព្រះចៅទីម៉ូតាប់ នៃប្រទេសអារ៉ាប់ ព្រះនាមកាឡាហ្វ បានសូមល្បងដោះប្រស្នាដែរ ដ្បិតទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធក្នុងរូបព្រះនាង ។

---

ព្រះនាងទូនរ៉ានដុក ទ្រង់មានព្រះសវនីយ៍ ដោយសេចក្ដីដូច្នេះថា :

– បពិត្រព្រះវររាជបិតា ខ្ញុំម្ចាស់មានសេចក្ដីសង្វេគណាស់ ដោយទតឃើញបុត្រព្រះមហាក្សត្រច្រើនព្រះអង្គ បានដល់នូវព្រះទិវង្គត ដោយ

សារតែរូបខ្ញុំម្ចាស់ សូមឲ្យទេវតាទាំងឡាយ ជាសាក្សីខ្ញុំម្ចាស់ផង ហេតុអ្វី ក៏បុត្រព្រះមហាក្សត្រទាំងនោះ ទ្រង់មានមានះសព្វព្រះហឫទ័យចង់បានខ្ញុំម្ចាស់ធ្វើជាមហេសីម៉្លេះ មិនទុកឲ្យខ្ញុំម្ចាស់គង់នៅជាសុខសាន្តក្នុងព្រះបរមរាជវាំងផង ហេតុអ្វី ទ្រង់ចេះតែមករុកកួន នូវសេរីភាពខ្ញុំម្ចាស់ ? ។ ! ព្រះរាជកុមារព្រហើនចចើងចង់លាកអើយ ទ្រង់ជ្រាបហើយថា ប្រសិនបើទ្រង់បានដល់នូវព្រះទិវង្គត ដោយឥតគ្រាប្រណី ដូចជាបុត្រព្រះមហាក្សត្រឯទៀតៗមុនទ្រង់នោះ កំហុសនេះ មិនមែនត្រូវធ្លាក់មកលើរូបខ្ញុំម្ចាស់ទេ គឺត្រូវធ្លាក់ទៅលើរូបទ្រង់ទាំងស្រុង ពីព្រោះគ្មាននរណាបង្ខំឲ្យទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធ ចង់បានរូបខ្ញុំម្ចាស់ទេ ។

ព្រះអង្គម្ចាស់ កាឡាហ្វ ទ្រង់ឆ្លើយតបវិញថា:

– បពិត្រព្រះអង្គម្ចាស់ក្សត្រីដ៏ទ្រង់លក្ខណ៍ ទូលបង្គំបានដឹងរឿងនេះអស់ហើយ ព្រះនាងទ្រង់មានព្រះសវនីយ៍យ៉ាងណា ក៏ចេះតែបាន ណ្ហើយ សូមព្រះនាងទ្រង់ចោទបញ្ហាមកចុះ ទូលបង្គំនឹងដោះថ្វាយតាមបន្ទាល់ ។

ព្រះនាង ទួនរ៉ានដុក ទ្រង់ចោទថា:

– បើដូច្នេះ តើធម្មជាតិអ្វី ជាក្តីមេត្រីនឹងយើងរាល់គ្នា លើលាគ្រប់ស្រុក ឲ្យសុខដល់អ្នកផង?

ព្រះអង្គម្ចាស់ កាឡាហូ ទ្រង់ដញ្ឆឹងមួយស្របក់ ទើបមានបន្ទូលឆ្លើយថា:

– បពិត្រព្រះអង្គម្ចាស់ក្សត្រីដ៏ទ្រង់លក្ខណ៍ ឯធម្មជាតិនោះ គឺព្រះអាទិត្យ ។

អ្នកប្រាជ្ញរាជបណ្ឌិតទាំងឡាយ ស្រែកសាទរឡើងថា:

– ព្រះអង្គម្ចាស់កាឡាហូទ្រង់ឆ្លើយត្រូវ គឺព្រះអាទិត្យមែនហើយ ។

ព្រះនាងទួនក៉ានដុក ទ្រង់ចោទតទៅទៀតថា:

– មាតាបែបនេះ គឺជាអ្វី: ប្រសូតបុត្រាបុត្រីក្នុងលោកបានធំហើយវេលាណា ត្រឡប់បរិភោគបុត្រទាំងនោះអស់ទៅវិញ?

ព្រះអង្គម្ចាស់កាឡាហូទ្រង់ឆ្លើយថា:

– មាតាបែបនេះ គឺមហាសមុទ្រ: ទឹកចំហាយហុយចេញពីសមុទ្រអណ្តែតទៅកកជាពពក ។ ធ្លាក់មកជាភ្លៀង ទឹកភ្លៀងហូរចូលទន្លេ ។ ហូរបាក់ធ្លាក់ទៅសមុទ្រវិញ ។

អ្នកប្រាជ្ញរាជបណ្ឌិត ព្រមទទួលថាចម្លើយនេះ ត្រូវម្តងទៀត ។ ចំណែកព្រះនាងទួនក៉នដុក កាលបើទ្រង់ជ្រាបច្បាស់ថា ព្រះអង្គម្ចាស់កាឡាហូ ទ្រង់ឆ្លើយត្រូវពីរដងដូច្នោះ ក៏ព្រះនាងទ្រង់នឹកខ្វាល់ក្នុងព្រះហឫទ័យយ៉ាងខ្លាំង ហើយទ្រង់ចង់ដណ្តឹងសួរព្រះអង្គម្ចាស់កាឡាហូឲ្យបានទាល់ ដើម្បីយកទោស ទើបទ្រង់ចោទបញ្ហាដ៏ពិបាកថែមទៀតថា:

— វត្ថុបែបនេះ អ្វីទៅក៉ មានស្លឹកផ្កាពណ៌សងខាង ម្ខាងស ម្ខាងខ្មៅ ។

មិនត្រឹមតែចោទសួរប៉ុណ្ណោះទេ ដើម្បីឲ្យព្រះអង្គម្ចាស់ទ្រង់ភាន់ភាំងព្រះស្មារតី ព្រះនាងថែមទាំងផាត់ស្បៃដែលបិទព្រះភក្ត្រចេញ ហើយបង្ហាញព្រះភក្ត្រស្រស់ត្រយង់ ប្រកបដោយព្រះនេត្រភ្លឺត្របះដូចដួងតារា ដែលអាការអៀនអន់ព្រះហឫទ័យខាងក្នុង បណ្តាលឲ្យរឹងរឹតតែល្អទៅឡើងទៀត ។

ព្រះអង្គម្ចាស់កាឡាហូ កាលបើបានទ្រង់ទតយល់ព្រះភក្ត្រព្រះនាងជាក់ច្បាស់ មានព្រះហឫទ័យប្រតិព័ទ្ធរឹតតែខ្លាំងឡើង ហើយទ្រង់ប្រថាប់ឈប់នៅទ្រឹង ភ្លេចព្រះអង្គ គ្មានមានព្រះបន្ទូលអ្វី ៗ ចំណែកខាង

អ្នកស្ដាប់ នាំគ្នាគិតភ័យជួសព្រះអង្គម្ចាស់យ៉ាងខ្លាំងពន់ពេក ។ ព្រះចៅអាទូនខាន់ ក៏ប្រែទឹកព្រះភ័ក្ត្រឡើងស្លេកស្លាំងដែរ ។ បានមួយស្របក់ព្រះអង្គម្ចាស់កាឡាហ្វ ទ្រង់ក្បាលជ្រងព្រះអង្គឡើងវិញ ទើបទ្រង់មានបន្ទូលថា:

– ទូលបង្គំ សូមទោសចំពោះព្រះអង្គម្ចាស់ក្សត្រី អម្បាញ់មិញនេះបានជាទូលបង្គំនៅស្ងៀម ដោយទូលបង្គំស្មានថា ហាក់ដូចជាបានឃើញស្រីទេវលោកសួគ៌ានាយ ប្រដាប់ដោយគ្រឿងអលង្ការដ៏ចើតច្បុតមក ។ ឥឡូវទូលបង្គំភ្ញាក់ចំណោទអស់ហើយ សូមព្រះនាងមេត្តាចោទមកម្ដងទៀត ។

ព្រះនាងទូរ៉ានដុក ទ្រង់មានព្រះសវនីយ៍ប្រាប់ថា:

– វត្ថុអ្វី មានស្លឹកផ្កាពណ៌សងខាង ម្ខាងស ម្ខាងខ្មៅ?

ព្រះអង្គម្ចាស់កាឡាហ្វទ្រង់ឆ្លើយថា:

– វត្ថុនោះ គឺឆ្នាំដែលមានថ្ងៃនិងយប់ជាប្រក្រតី ។

ការដោះស្រាយនេះត្រូវទៀត ។ អ្នកចាំស្ដាប់ទះដៃគឹលឡើង ហើយខ្សឹបគ្នាសរសើរដល់ព្រះអង្គម្ចាស់កាឡាហ្វពល់មាត់ ។ ព្រះចៅអាទូនខាន់ មានព្រះបន្ទូលទៅកាន់ព្រះរាជបុត្រីទូរ៉ានដុកថា:

– ម្នាលព្រះនាង! ព្រះនាងល្មមសព្វព្រះហឫទ័យចុះចាញ់ហើយឬនៅ គួរព្រះនាងព្រមទទួលយកព្រះអង្គម្ចាស់នេះ ធ្វើជាព្រះស្វាមីឬទេ? បិតាមិនដែលទតឃើញព្រះអង្គម្ចាស់អង្គណា រកចំណោទឃើញមួយទេ ឯព្រះរាជកុមារនេះ អាចរកចំណោទរបស់ព្រះនាងបានឃើញទាំងអស់ ។

ដកស្រង់ពីរឿងអាក់ប់

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ប្រតិព័ទ្ធ ។ ២) សវនីយ៍ (សៈវៈណី) ។ ៣) សង្វេគ ។ ៤) ទិវង្គត ។ ៥) មានះ ។ ៦) សុខសាន្ត ។ ៧) បបើងបង់លាក ។ ៨) ទ្រង់លក្ខណ៍ ។ ៩) តាមបន្ទាល់ ។ ១០) ក្ដីមេត្រី ។ ១១) ប្រសូត ។ ១២) រុក្ខា ។ ១៣) ដួងតារា ។ ១៤) ទេវលោកសួគ៌ាល័យ ។ ១៥) អលង្ការ ។ ១៦) ច្បុត ។

## ខ) សំនួរ

១) ព្រះនាងទូនរ៉ាន់ដុក មិនសព្វព្រះហឫទ័យ នឹងមានព្រះស្វាមីទេឬ? ២) អ្វីដែលនាំឲ្យបុត្រព្រះមហាក្សត្រច្រើនអង្គ បានដល់នូវព្រះទិវង្គត? ៣) ចម្លើយទី ១ នៃព្រះអង្គម្ចាស់កាឡាហ្វ ត្រូវមែនឬទេ? ព្រោះ

ហេតុអ្វី? ៤) សេចក្ដីក្នុងអត្ថបទត្រង់ណា ដែលសឲ្យឃើញថា ព្រះនាងទួនពីនផុក មិនសព្វព្រះហឫទ័យនឹងមានព្រះស្វាមី? ៥) សេចក្ដីត្រង់ណាខ្លះ បញ្ជាក់ឲ្យឃើញថា មហាជនពេញចិត្តជាខ្លាំង ទៅលើព្រះអង្គម្ចាស់កាឡាហូ? ៦) ចូរអត្ថាធិប្បាយនូវប្រស្នាទី ៣

## គ) ផែនការ

អត្ថបទនេះ ចែកជាប៉ុន្មានសង្កាត់? ចូរឲ្យនាមដល់សង្កាត់នីមួយៗ ។

## ឃ) វេយ្យាករណ៍

១) ចូររកក្នុងនិទាននេះ នូវពាក្យអសាធារណនាម មនុស្សពីរ នឹងពាក្យសាធារណនាម មនុស្សបួន ។

២) ចូររកពាក្យព្យាង្គតម្រួតប្រាំ នឹងពាក្យពីរព្យាង្គប្រាំ ។

---

## បទនគររាជ

សូមពួកទេវតា រក្សាមហាក្សត្រយើង
ឲ្យបានរុងរឿង ដោយជ័យមង្គលស្រីសួស្ដី

យើងខ្ញុំព្រះអង្គ   សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះនរបតី   វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ   បូកណាថ្កើងថ្កាន ។
ប្រាសាទសិលា កំបាំងកណ្ដាលព្រៃ
គួរឲ្យស្រមៃ នឹកដល់យសសក្ដិមហានគរ
ជាតិខ្មែរដូចថ្ម គង់វង់នៅល្អ រឹងប៉ឹងជំហរ
យើងសង្ឃឹមថា ក័ព្យព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ ។
គ្រប់វត្តអារាម ឮតែសូរសព្ទធម៌
សូត្រដោយអំណរ រំលឹកគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រ តាមបែបដូនតា
គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្គត់ផ្គង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ ។

សម្ដេច ព្រះមហាសុមេធាធិបតី ជួន–ណាត

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ជ័យមង្គល ។ ២) ស្រីសួស្ដី ។ ៣) ព្រះបារមី ។ ៤) ប្រាសាទសិលា ។

## ខ) សំនួរ

១) ហេតុអ្វីបានជាអ្នកនិពន្ធ ថាខាងដើមបន្ទស់នៃបទនគររាជនេះ សូមឲ្យទេព្ដាបម្រុងបម្រើនជ័យមង្គលដល់ព្រះមហាក្សត្រយើង? ២) ព្រះមហាក្សត្រយើង តព្រះវង្សពីព្រះមហាក្សត្រជំនាន់ណាមក? ៣) ក្នុងសម័យបុរាណជំនាន់ណា ដែលប្រទេសកម្ពុជាយើងរុងរឿងជាងគេ? ៤) អ្នកនិពន្ធថា: «ប្រាសាទសិលា កំបាំងកណ្ដាលព្រៃ» តើមានបំណងនឹករកទៅប្រាសាទឯណា? ៥) ពាក្យថា: «ជាតិខ្មែរដូចថ្ម រឹងប៉ឹងជំហរ» តើសំដីនេះត្រូវពិតមែនឬទេ ហើយបានជាដូច្នេះ តើដោយស្នាព្រះហស្ដដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រអង្គណា? ៦) ពាក្យថា: «គ្រប់វត្តអារាម ឮតែសូរសព្ទធម៌» តើជាសូរសព្ទធម៌នៃសាសនាណា? ៧) តើព្រះពុទ្ធសាសនា មានគុណយ៉ាងណាខ្លះ ដល់អ្នកដែលគោរពប្រតិបត្តិតាម?

## គ) ផែនការ

កំណាព្យនេះ គេអាចចែកជាប៉ុន្មានសង្កាត់? — ក្នុងសង្កាត់នីមួយៗ គេពោលពីអ្វី?

## ឃ) វេយ្យាករណ៍

១) ស្រី (ស្រីសួស្តី) ជាភាសាអ្វី? មានន័យដូចម្តេច? ២) ចូរស្រង់ពាក្យណាខ្លះ ដែលក្លាយមកពីភាសាបាលី ក្នុងកំណាព្យនេះ? ៣) ចូររកពាក្យវេវចនៈនឹង «សិលា» — «នរបតី» ។

---

ភ្នំពេញ
រោងពុម្ពក្រសួងឃោសនាការជាតិ